# សំណៀងកំណាព្យ




រៀបរៀងដោយ

ខ្ញុំព្រះកុរណា សាមណេរ

ខន្តិសារោ ស៊ិន អង្គរា


សម្រាប់ធម្មទាន

# ពាក្យបំភ្លឺ

ហេតុឱ្យសៀវភៅចេញជាពាក្យកាព្យ
សំនៀងកំណាព្យនេះកើតឡើងណា
គឺខ្ញុំនេះផ្ចាល់មានចិត្តជ្រះថ្លា
នឹងចង់រក្សាកេរ្តិ៍ដូនតាផង ។
ម្យ៉ាងទៀតចង់ក្រើនដល់អស់ព្រះសង្ឃ
បួសដោយចិត្តផ្ងង់គ្មានក្តីសៅហ្មង
ដើរតាមបិតាគឺពុទ្ធអង្គផង
ដើរតាមគន្លងវិនយាធម្មា ។
និងក្រើនរម្លឹកដល់កូនប្រុសស្រី
ដែលធ្លាប់ពោលស្តីតម្លើងចិត្តពៀរ
ចំពោះម៉ែឪដែលល្អសោភា
ឥឡូវសូមរាដៃថាឈប់ហើយ ។
ម្យ៉ាងទៀតឪម៉ែទាំងឡាយគ្រប់ប្រាណ

ប្រណីសន្តានដល់កូនត្រាណត្រើយ
កុំបង្ខំកូនឱ្យទៅកៀកកើយ
បានប្តីដូចខ្នើយតែក្តៅដូចភ្លើង ។
សូមអស់កូនចៅទាំងប្រុសនិងស្រី
សូមលោកប្រណីកុំញ៉ែរដៃជើង
បើសិនខ្ញុំខុសកុំខឹងកុំឆ្មើង
មានចិត្តល្អឡើងជួយកែខ្ញុំផង ។
ថានៃ៎លោកក្មួយត្រង់នេះមិនសម
សូមក្មួយឯងខំកុំឱ្យមានឆ្គង
នៅពេលក្រោយទៀតណាក្មួយស្នេហ៍ស្នង
អរគុណទុកផងបើបែបនេះមែន ។

**ថ្ងៃច័ន្ទ ១៥ កើត ខែមាឃ ឆ្នាំរោង ចត្វាស័ក ព.ស.២៥៥៦**
**ពីបំណងល្អដ៏បរិសុទ្ធរបស់ខ្ញុំ ស៊ិន អក្ខរា**
*ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ*

# ១-ស្មោះនិងខ្លួនឯង



យើងស្រឡាញ់គេថែមទាំងស្មគ្រស្មោះ
កត់ត្រាចេញអស់ពីដួងហ្ឫទ័យ
នៅទីបំផុតត្រូវបានបរាជ័យ
អសារឥតន័យនៅក្នុងជីវិត ។
ទោសៈនាំឈ្លោះមោហៈវង្វេង
លោភៈជាក់ស្តែងជាប់ហើយថែមស្អិត
ឥស្សាច្រណែនហួសបើនឹងគិត
ទិដ្ឋិខុសពិតញាតិគ្នាអបាយ ។
កោធាចិត្តអន់មទៈស្រវឹង
រាគៈរំពឹងឥតរសាយ
វិបល្លាសឥតគង់មិនដែលជិនណាយ
ដោះស្រាយមិនបានសែនអន្ទការ។
ដូច្នេះសូមចាំត្រូវប្រឹងកោតក្រែង
ស្មោះនិងខ្លួនឯងស្មគ្រដោយបញ្ញា

នៅលើលោកិយ៍គឺគ្មាននរណា
ស្មោះជាងអាត្មារបស់អ្នកឡើយ ។
ទានសីលភាវនាអមនិងកុសលា
និងធម៌ទេសនានាំទៅកាន់ត្រើយ
ស្មោះនិងបណ្ដិតជីវិតនឹងល្ហើយ
នេះពិតបានស្បើយនាំខ្លួនរួចទុក្ខ ។

**ជោសុិន អក្ខរា ព.ស២៥៥៦**

# ២-ស្នេហានិងបុណ្យ



ស្នេហាបក្សពួកមិត្តនិងសុខទុក្ខ
ប្រុសស្រីស្មាញស្មុគគ្រប់ពេលវេលា
ខ្លះអស់ជីវិតមិនគ្រប់ជន្មា
លាមិត្តបងប្អូនចាកចោលលោកា ។
តណ្ហាស្នេហាប្រុសហើយនិងស្រី
រាគៈអប្រិយ៍ដុតរោលចិន្តា
អនុស័យសម្ងំពួនក្នុងអាត្មា
រយម៉ឺនខ្លោចផ្សារយលានអំពល់ ។
តណ្ហាប្រុសស្រីនាំឱ្យល្មើសគុណ
ឱ្យបំភ្លេចបុណ្យនាំជួបអកុសល
ស្នេហ៍នេះសែនខុសគឺស្នេហ៍សំណល់
រងកម្មជួបខ្វល់ទៅជាតិនានា ។
ស្នេហានិងបាបមុខទៅអវិចី
ធ្វើឱ្យប្រុសស្រីមានសោកក្រំគ្រោ

បានកើតជាតិណាជីវិតរងា
ជាជនកំព្រាព្រោះត្រូវទារុណ ។
ដូច្នេះប្រុសស្រីគ្រប់ៗអាត្មា
អ្នកត្រូវរអាស្នេហានឹងបុណ្យ
នោះទើបបានល្អសន្សំដើមទុន
លែងឈឺឈប់គ្រុននៅនាជាតិថ្មី ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៣-មាត់ខ្លាច ចិត្តខ្លាំង



ទន់ក្រៅរឹងក្នុងមិនល្អទាំងស្រុង
អ្នកគួរតែប្រុងប្រយ័ត្នសោកស្តាយ
អយោនិសោ.ពិតមិត្តក្លែងក្លាយ
មាត់ថាសែនណាយតែចិត្តសែននឹក។
មាត់ថាណាយបាបតែចិត្តធុញបុណ្យ
មាត់ថាដឹងគុណចិត្តសំពឹក
មាត់ពោលពាក្យផ្អែមចិត្តពស់ សន្ធឹក
ម៉ែឪលែងនឹកព្រោះបានតែថា ។
មាត់ពោលថាខ្លាចតែចិត្តអញខ្លាំង
ឆន្ទៈប្រឆាំងរួមនិងហិង្សា
មាត់ថារួចពៀរតែចិត្តទោសា
ព្យាបាទអស្ចារ្យតជាតិភពថ្មី ។
មាត់ខ្លាចព្រះសង្ឃតែចិត្តដៀលជេរ

គ្មានពេលទំនេរឥតត្រាប្រណី
មាត់ដូចទឹកឃ្មុំមនោអប្រិយ៍
មុខអ្នកដទៃថាសង្ឃគុណណាស់។
ហៃ!សាធុវោ!រីអស់បរិស័ទ
គួរប្រុងប្រយ័ត្នកែចិត្តដែលឆ្នាស់
មុនពោលចរចារគិតឱ្យក្រៃក្រាស់
ទើបមិនផ្តេសផ្តាសពិតញាតិសប្បុរស។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៤-ស្អប់គេស្មើស្អប់ខ្លួនឯង



កើតមកជាមនុស្សមិនគួរសាងពៀរ
ព្រោះរឿងវេរាមិនមែនល្អឡើយ
មិនមែនកន្ទេលមិនមែនជាខ្មើយ
ដូច្នេះអ្នកអើយគួរមានមេត្តា ។
សន្តោសាគុណសែនល្អប្រណិត
សមនិងជីវិតកើតពីកុសលា
អង្គប្រាណបានល្អព្រោះគុណបុញ្ញា
ពាក្យសន្តោសាសន្តោសប្រណី។
វេរានាំសោកនាំឆ្ងាយសួគ៌ា
នាំឱ្យក្រំគ្រាជីវិតប្រុសស្រី
ដូច្នេះកុំស្អប់ចំពោះអ្វីៗ
ទាំងជនប្រុសស្រីកុំស្អប់ដៃរណា។
ព្រោះបើស្អប់គេស្មើស្អប់ខ្លួនឯង

ឱ្យខ្លួនចំបែងតែងរែងខ្លោចផ្សា
ឥតមានអ្នកប្រោសគ្មានញាតិទេវតា
អសប្បុរិសាបានជាញាតិជៅ។
បណ្តែតចិត្តល្អតាមបុញ្ញរាសី
មេត្តាប្រណីតាមពាក្យប្រដៅ
សុភាសិតោវាចាន័យជ្រៅ
លែងសោកហ្មងសៅគ្រប់ៗជាតិអើយ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៥-ជ្រោះកម្ម



នៅក្នុងត្រៃភពនាលោកិយ៍
រឿងរ៉ាវអប្រិយ៍ច្រើនអស្ចារ្យ
បញ្ជាវេរជាប់ឱរា
លើកដៃប្រហារហួសការស្មាន ។
ជ្រោះពីលើភ្នំខ្ពស់ក្រាស់ក្រៃ
អាចនឹងប្រលែឱ្យក្ស័យបាន
មើលឃើញព្រឺរោមពន់ប្រមាណ
ជនទាំងប៉ុន្មានឥតចង់ធ្លាក់ឡើយ ។
តែទោះបើធ្លាក់ក៏មិនអី
មិនធ្លាក់អវិចីទេអ្នកអើយ
ស្លាប់ត្រឹមតែរូបចិត្តនៅកើយ
បុណ្យយើងបានសោយអត់បញ្ហា ។
រីឯជ្រោះកម្មអាក្រក់ក្រៃ
នរណាចាប់ដៃលេងកាលណា

ពិតជាឆក់ទាញឱ្យទុក្ខា
នឹងត្រូវខ្លោចផ្សាក្នុងជ្រោះកម្ម ។
ដូច្នេះកុំលេងនៅមាត់ជ្រោះ
ប្រយ័ត្នរងគ្រោះពិតប្រៃស្រាំ
អកុសលទុយ៌សនោះគឺកម្ម
រូបខ្ញុំសូមផ្តាំកុំលេងកម្មអី ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៦-ធ្វើខ្លួនឱ្យគួរស្រឡាញ់បែបណា?



បើមុខកើតមុនត្រូវតែលាបម្សៅ
បើរូបកាយក្តៅត្រូវតែងូតទឹក
បើចិត្តប្រែប្រួលត្រូវរលឹក
បើខ្លួនសំពឹកត្រូវតែឧស្សាហ៍ ។
បើចង់ឆ្ងាយបាបត្រូវតែធ្វើបុណ្យ
បើមិនដឹងគុណត្រូវភ្ញាក់អាត្មា
បើចិត្តចេះស្អប់ត្រូវតែស្នេហា
បើខ្លាចទុក្ខាត្រូវតែចម្រើនសុខ ។
យ៉ាងណាបើអ្នកចង់ធ្វើខ្លួន
ស្រឡាញ់មាំមួនជាតិនេះជាតិមុខ
ត្រូវឱ្យមានសីលភាវនាតាំងទុក
ខ្លួននឹងស្រណុកឆ្ងាយបញ្ហាវេរា ។
សូមកុំច្រឡំរឿងផ្សេងអី
តែសូមប្រុសស្រីចាំគ្រប់ៗគ្រា

មិនមែនអលង្ការគ្រឿងសោភា
ប្រុសស្រីនានាពិចារណាផង ។
ត្រូវធ្វើខ្លួនអ្នកឱ្យសមជាមនុស្ស
កុំបីប្រទូសទើបមិនមួហ្មង
នឹងឈ្មោះស្រឡាញ់ខ្លួនអ្នកតែម្តង
ខ្លួនលែងឆ្កាំឆ្គងលែងមានកំហុស។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៧-ម៉ែអើយអាសូរកូនស្រីផង



ស្រស់ស្រីក្រមុំទួញសោកា
ព្រោះតែមាតាបិតាមិនយល់
បង្ខំឱ្យនាងរងក្តីអំពល់
ដើមទ្រូងចុកសល់ម៉ែឱ្យមានប្តី ។
អ្នកខ្លួនស្រឡាញ់បែរមិនបាន
ព្រោះម្តាយរុញច្រានឥតប្រណី
មិនដែលធ្លាប់ស្គាល់ម្តាយចាប់ស្រី
ឱ្យនាងបានប្តីមិនដែលយល់ចិត្ត ។
ឃើញគេមានលុយម៉ែខ្វល់ហួស
កូនស្រីរបួសស្ទើរសូន្យជីវិត
អាងខ្លួនជានាឡនាងនំខូចចិត្ត
សោភាមាសស្និទ្ធចូលជ្រោះកម្ម។
នាងសោកនាងយំសឹងលីលា
បាត់បង់ឫកពាដួងចិត្តប្រេះស្រាំ

មិនហ៊ានថាម៉ែព្រោះចាស់ផ្តាំ
នាងស៊ូតាមកម្មជាតិនេះចុះ ។
មាតាបិតាសូមប្រណី
ស្រណោះនាងស្រីដោយចិត្តស្មោះ
សួរចិត្តនាងផងកុំបីឈ្លោះ
ជួយនាងផុតគ្រោះទើបត្រូវច្បាប់។
ការរើសគូគ្រងនៅលើមាតា
តែក្តីស្នេហាលើនួននាងត្រាប់
ស្នេហ៍ចេញពីចិត្តមិនស្រអ័ព្ទ
តែបើប្រញាប់នាងពិតសោកា ។
ព្រោះតាមចិត្តម្តាយទើបនាងខុស
ធ្វើឱ្យស្រីប្រុសជេរដៀលថា
មេម៉ាយពីក្មេងព្រោះមាតា
បង្ខំឱ្យការខ្លាចគ្មានថៅ ។
ចង់បានថៅពេកមិនគិតស្រី

នាងឈឺឥតបីក្នុងគ្រោះជ្រៅ
នាងរស់ស្តាយកម្មដិតសំណៅ
នេះហើយគេហៅនាឡធំជាងនំ ។
ឱ!ពុកម៉ែអើយកុំហិង្សា
មិនត្រូវផ្តាសាដល់ស្រីមុំ
បើនាងតវ៉ាឆ្លើយពាក្យកុំ
សូមជួយស្អាងស្ពំឱ្យនាងផង ។
បើមិនដូច្នោះគង់សោកា
នាងនឹងមរណាអ្នកនឹងហ្មង
វិបល្លាសចុងក្រោយអ្នកនឹងឆ្គង
កូនស្រី១ផងត្រូវស្លាប់ចោលម្តាយ។
នេះព្រោះតែអ្វីនិងនរណា
នោះគឺមាតាគិតមិនបានឆ្ងាយ
គ្រាន់ឃើញគេមាននិងឡួយឆាយ
មិនគិតនាយអាយចាប់នាងចង ។

រីម្តាយខ្លះទៀតលួងធ្វើហំ
លើដៃប្រណមទៅទងវង
សូមចិត្តកូនស្រីអាសូរផង
យកទៅនួនល្អងកុំនៅយូរអី ។
អាងតែខ្លួនចាស់ប្រឹងវាចា
សូមនាងស្នេហាឆាប់យកប្តី
គេមានគេល្អណាកូនស្រី
បើកូនបានប្តីស្លាប់បិទភ្នែកជិត ។
រីកូនក្រមុំឃើញកាយវិកា
ហារចេញវាចាមិនរួចពិត
ព្រោះតែឃើញម្តាយអង្វរចិត្ត
ណាលើកដៃស្និទ្ធសំពះខ្លួនផង ។
ហារទៅពិតស្លាក់ខ្ជាក់នឹងស្លែង
ស្តោះលើទ្រូងឯងនាងស៊ូហ្មង
តាមចិត្តម្តាយខុសចិត្តគិតប៉ង

ជាតិនេះខុសម្តងជាតិក្រោយលា។
ខ្ញុំមិនអធិប្បាយទៅទៀតឡើយ
សូមអស់រូបម្តាយផងនានា
កុំខឹងនិងខ្ញុំនាំមានវេរា
សូមម្តាយគ្រប់គ្នាគិតឱ្យច្បាស់ ។
អ្វីដែលខ្ញុំពោលមិនចិត្តឯង
ខ្ញុំឮជាក់ស្តែងឥតក្រឡាស់
គេប្រាប់ខ្ញុំផ្ទាល់ចំៗណាស់
ច្នេះខ្ញុំមិនផ្តាសចេះតែថាឡើយ ។
រូបនាងនៅក្មេងតែស្រីមេម៉ាយ
នេះមកពីម្តាយគ្រប់គ្នាហើយ
ដែលចាប់កូនការឱ្យដល់ត្រើយ
ចុងក្រោយស្អុយឈ្មោះកេរ្តិ៍ដូនតា។
ខ្ញុំសូមអភ័យប្រណីទោស
គ្រប់ម្តាយសន្តោសដល់អក្ខរា

# បើពិតកុំខឹងសូមកែចិន្តា
# ទើបឈ្មោះមាតាគ្រងតាមធម៌ ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៨-វិស័យអ្នកផ្សារ

( បិដកលេខ ៤៣ )



ជនអ្នករកស៊ីជួញផ្លាស់ប្តូរ
ចេញហើយនិងចូលគ្រប់វេលា
ជំនួញធំតូចតឹងធូរធារ
ឥតបីរួញរាបន្តិចឡើយ ។
ប្រឹងយប់ប្រឹងថ្ងៃមិនរអា
បំពេញកិច្ចការពុំមានស្បើយ
ទាំងប្រុសនិងស្រីគិតរកត្រើយ
ចង់ឱ្យបានហើយឆាប់មានផង ។
ខ្ញុំសូមលើកយកពីអ្នកផ្សារ
អង្គ៣ប្រការមិត្តចូរចាំចង
១ចំណេះដឹងអ្នកផ្សារទាំងផង
ទើបងាយឃុំគ្រងមិនអន្តរាយ ។
២គឺវិរិយាមិនស្រាកស្រាន្ត

ព្យាយាមគ្មានខានខំនាយអាយ
ដាស់តឿនខ្លួនថាកុំរសាយ
នោះនឹងមានហើយព្រោះវិរិយា។
៣គឺសម្បូរនូវទីពឹង
បាននូវពុំនឹងយ៉ាងមហិមា
អ្នកមានអ្នកធំដូចជានាវា
ជួយអ្នកគ្រប់គ្រាទោះពេលណា។
ដូច្នេះអ្នកធ្សារទាំងប្រុសស្រី
ត្រូវចាំអង្គបីណាអ្នកណា
អ្នកនឹងចម្រើនទ្រព្យកើនអស្ចារ្យ
លែងក្រហើយណាលុះអវសាន្ត ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៩-បង្រៀមាតាបិតា
# គឺសន្សំសុខឱ្យខ្លួនឯង



បានកើតមកហើយលើលោកា
មាតាបិតាបានឱ្យកំណើត
ចិញ្ចឹមបម្រើឱ្យមានរូបឆើត
ល្អស្រស់ដូចខ្នើតពេញបូណ៌មី ។
ដូច្នេះគួរកូនផងនានា
ស្តងកុំបីរាទាំងប្រុសស្រី
មើលឃើញគុណព្រះល្អគ្មានពីរ
ស័កសមសោភីពេលធំប្រាណ ។
ដំណើរបណ្ឌិតនៅលើលោកិយ៍
មហាព្រះអរិយ៍ទ្រង់តែងបាន
បំពេញពុទ្ធកិច្ចយ៉ាងចំណាន
តបធ្វើឥតស្រាន្តលុះបានត្រាស់ ។

ទោះទ្រង់បានត្រាស់ជាព្រះពុទ្ធ
ធ្វើឥតស្រយុតទ្រង់ឥតក្រឡាស់
មិនឃើញអ្នកផ្សេងដែលល្អល្អះ
ប្រសើរក្រៃក្រាស់ជាងនោះទេ ។
មាតាបិតាសែនល្អប្រពៃ
កូនគួរលកលែបង្កើតចិត្តស្នេហ៍
ស្នេហាគោរពទុកជាកេរ្តិ៍
បានពូជមន្តស្នេហ៍នៅជាតិថ្មី ។
ប្រឹងលើកលោកដាក់នឹងបូជា
ព្រឹកល្ងាចវន្ទាដោយភក្តី
នំនិងអាហារដែលមានថ្មី
មេត្តាប្រណីលើកជូនឥតស្រាន្ត ។
ព្រោះលោកនេះហើយគឺជាព្រះ
កូនគួរសំពះបន្ទន់ប្រាណ
គារវៈចិត្តផ្ងង់ពិតចំណាន

ប្រាណអ្នកបានស្បើយពីកង្វល់ ។
មានជ័យបានជោគកាលរស់នៅ
ទោះបីស្លាប់ទៅពិតមិនខ្វល់
បរៈបរាជ័យអស់លែងសល់
ទោះមារមានកលនៅតែចាញ់ ។
អានិសង្សបដិបត្តិនឹងមាតា
ជាមួយបិតាដែលយើងគិតកាញ់
ប្រឹងប្រែងបមបីចិត្តស្រឡាញ់
គេស្នេហ៍នឹងដេញចូលចិត្តពិត ។
ទេវតាទាំងមឺននឹងតោងរក្សា
ចំពោះកូនណាដែលប្រព្រឹត្ត
ប្រណិប័តន៍នឹងព្រះដ៏ពិសិដ្ឋ
ទេវតាមូលមិត្តគ្រងគ្រប់ទី ។
តាំងពីជីវិតដែលរស់នៅ
រហូតស្លាប់ទៅពីផែនដី

ញាតិមិត្តអ្នករស់ទាំងប្រុសស្រី
នឹកអ្នកឥតបីព្រោះកតញ្ញូ ។
គេទៅកន្លែងណាទោះនាយអាយ
គេនឹងបរិយាយមិនរអ៊ូ
គេនឹងសរសើរអ្នកជាគំរូ
អស់មាមីងពូប្រឹងធ្វើត្រាប់ ។
ដូច្នេះកូនៗផងទាំងឡាយ
សូមប្រឹងកែកាយវាចាចិត្តច្បាប់
ដើរតាមបណ្ឌិតកុំក្រឡាប់
ហើយត្រូវប្រញាប់កុំលះហោង។
**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ១០-អារសាច់ជូនម្តាយ មិនរួចកម្មពៀរ



មានបទចម្រៀងបានច្រៀងថា
ប្រកាសវាចាកូនសូមអារសាច់
ជូនម្តាយមានគុណល្អឥតបំណាច់
ព្រោះត្រូវស្រីកាច់-ក-ហុតឈាម ។
ស្នេហាស្រីបោកទើបភ្ញាក់ប្រាណ
ថាគេសាមាន្យថោកកាកី
តាមពិតខ្លួនក្រគ្មានអ្វីៗ
នាងមិនភក្តីតាមពិតខ្លួនឯង ។
ឈឺចិត្តព្រោះស្នេហ៍ខុសបំណង
ណា១ធ្វើឆ្គងឱ្យម្តាយចំបែង
រត់ចោលម្តាយថ្លៃពុំខ្លាចក្រែង
ចិត្តឥតរអែងនឹងអ្នកមានគុណ ។

ទើបភ្ញាក់អាត្មាតាំងចិត្តអារសាច់
ទោះឈឺប្រកាច់ត្រូវទារុណ
ខាំមាត់អត់ទ្រាំស្លាប់ក្រោយមុន
សូមទោសស្រាលធ្ងន់រលាយទៅ។
តែទោះយ៉ាងណាការធ្វើបែបនេះ
ខ្ញុំសូមឈ្នានីសទោះកូនចៅ
គឺគ្មានប្រយោជន៍គ្មានគោលដៅ
រឹតសោកហ្មងសៅឈឺក្រំគ្រា ។
អ្វីដែលអ្នកធ្វើខ្វះបញ្ញា
ប្រាសចាកប្រាជ្ញាឱ្យមានវេរា
ថែមគ្មានអ្នកជួយអ្នកពិតកំព្រា
រស់ហើយរងាទុក្ខឥតស្រាន្ត ។
ដូច្នេះកូនៗសូមមានបញ្ញា
ធ្វើឱ្យមាតាបិតាសុខសាន្ត
គឺធ្វើឱ្យគាត់កាយចិត្តសុខត្រាណ

ផុតពៀរប៉ុន្មានលែងមកជិត
ត្រូវធ្វើតាមធម៌តាមវិន័យ
ចិត្តអ្នកវិនិច្ឆ័យល្អថែមស្និទ្ធ
ណាត្រូវឬខុសចោលមួយពិត
យកល្អមកជិតដាក់សន្តាន ។
ទានសីលភាវនាសម្មាទិដ្ឋិ
សោភណៈសតិកើតចំណាន
នាំម៉ែនិងឪទៅកាន់ឋាន
សុខសួគ៌ក្សេមក្សាន្តនានិព្វាន ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ១១-អាណិតខ្លួនតែធ្វើបាប



មាត់ខំពោលថាអាណិតខ្លួន
អាណិតខ្លួនតែមិនដែលបាន
មិនបានធ្វើល្អទុកក្នុងប្រាណ
ក្នុងប្រាណត្រឹមបានទុក្ខសោកា ។
សោការឹតខ្លាំងធ្វើតែអកុសល
អកុសលអំពល់កៀកអាត្មា
អាត្មារីងរៃនឹងខ្លោចផ្សា
ខ្លោចផ្សាគ្មានស្រាន្តក្នុងជីវិត ។
ជីវិតទុយ៌សក្នុងលោកិយ៌
លោកិយ៌គ្មានអ្វីបន្សល់ពិត
ពិតតែក្លែងក្លាយនិងប្រឌិត
ប្រឌិតមិនគិតដំណោះស្រាយ ។
ឃើញខ្លួនក្រក្រីមិនដែលមាន
មានចិត្តស្រែកឃ្លានហួសនិយាយ

និយាយលែងត្រូវព្រោះចិត្តធ្លាយ
ចិត្តធ្លាយសាងបាបបន្តទៅ ។
កែខ្លួនមិនបានឃើញតែខុស
តែខុសកំហុសតកូនចៅ
កូនចៅធ្វើត្រាប់ជាដំបៅ
ដំបៅគឺកម្មប្រចាំប្រាណ ។
ចិត្តគិតកាលណាអាណិតខ្លួន
អាណិតខ្លួនណាស់ខំពុំស្រាន្ត
បញ្ចូរោជាចង្រ្កាន
ចង្រ្កានមុខបីគឺត្រៃភព ។
បើអ្នកធ្វើបាបពិតមិនមួន
មិនមួនខុសក្បួនខុសប្រសព្វ
ប្រសព្វរឿងខុសពិតអភ័ព្វ
អភ័ព្វលុះក្ស័យទៅជាតិថ្មី ។
បាបមិត្តរុកកៀកនៃជីវិត

ជីវិតពិតស្ថិតវិបដិសារី

វិបដិសារីជាអវិចី

អវិចីគ្មានសុខតែទុក្ខហួសស្មាន ។

អ្នកបួសក្រហស្តទាំងប្រុសស្រី

ប្រុសស្រីចាស់ខ្ចីគ្រប់ទីស្ថាន

ទីស្ថានមានក្រួចមិនបាន

មិនបានរួចប្រាណពីទុក្ខឡើយ ។

បើអាណិតខ្លួនកុំធ្វើបាប

ធ្វើបាបឈ្មោះថាអ្នកកន្តើយ

កន្តើយឋានសួគ៌ណាអ្នកកើយ

អ្នកកើយគួរគិតរើសសួគ៌ា ។

នាំខ្លួនទៅឆ្ងាយពីកង្វល់

កង្វល់ធ្លាប់មាននិងវេរា

វេរាតូចធំប្រញាប់លា

លាហើយរូបអ្នកត្រូវអស់ទុក្ខ ។

# ដោយសុិន អក្ខរា ព.ស.២៥៥៦



# ១២-ស្នេហារកច
# បំបែកមិត្តភាពបាន



រូបខ្ញុំកវីនាមសុិនអក្ខរា
រៀបចំចែងចារនៅថ្ងៃសុក្រ
ថ្ងៃ៦រោចខ្ញុំមិនសំកុក
ដោះក្តីស្នាញស្មុគបានជាជំនួយ ។
ត្រូវថ្ងៃទី៣ខែមករា
សរសេរកត់ត្រាដោយក្តីទុក្ខព្រួយ
ព.ស.២៥៥៦
ជាការលើកស្ទួយដល់ចិត្តប្រុសស្រី ។
ប្រកាសតាមពិតខ្ញុំឥតបន្លំ
ស្នេហាស្អាតស្អំនិងល្អឥតបី
ផ្អែមល្ហែមពុំល្អៀងសែនបេតី
ទោះមានក្រក្តីនៅមានស្នេហា ។

អ្នករាប់អានគ្នាពីក្មេងវ័យ
ភ្ជាប់ដោយនិស្ស័យនិងកុសលា
បុណ្យពីបុព្វេផងដែរណា
ទើបចាប់ហត្ថារាប់អានគ្នា ។
អស់ជាច្រើនឆ្នាំស្ម័គ្រអភ័យ
សឹងអាចថាក្ស័យទៅជាតិនានា
មិត្តប្រុសនិងស្រីស្មោះពុំរា
ឥតបីមានមារបំបែកបាន ។
មិត្តប្រុសនិងប្រុសគ្រប់នាទី
ស្រីហើយនិងស្រីប្រឹងរាប់អាន
ទោះល្ងាចទោះយប់ជួបគ្នាបាន
ទុកស្មើនិងប្រាណឬកែវនេត្រា ។
មិនយូរប៉ុន្មានស្នេហ៍មកដល់
កើតក្តីមិនយល់ប្តឹងតវា
ធ្លាប់រាប់អានគ្នាប្តូរសង្វារ

ឥឡូវប្រែឆាព្រោះស្នេហ៍អប្រិយ៍ ។
តណ្ហាលោភៈទោសៈហិង្សា
ច្រណែនឫស្សាខឹងប្រុសស្រី
ឈ្លោះខឹងនិងគ្នាពុំពោលស្តី
ព្រោះស្នេហ៍នាំភ័យដល់ផ្លូវបែកគ្នា ។
ធ្លាប់តែសន្យាថាមិនអី
ទោះរឿងក្រក្រីយើងកុំរួញរា
ឥឡូវបាត់អស់បែរចងពៀរ
ចំណងវេរាអាឃាតអវសាន្ត ។
នេះមកពីស្នេហ៍សូមញាតិជៅ
និងអស់កូនចៅគ្រប់ៗប្រាណ
មិនមែនព្រោះប្រុសអ្នករំខាន
ឯស្រីមិនបានបំបែកគ្នាឡើយ ។
គឺមកពីស្នេហ៍នាំជម្លោះ
នាំអ្នករងគ្រោះពុំស្រាកស្បើយ

ឈប់មើលមុខគ្នាបែរកន្តើយ
ចិត្តនាំប្រងើយលុះមរណា ។
ដូច្នេះអស់មិត្តផងនានា
គិតកុំបីរាកុំរអា
គិតហើយចាំគូរដោយបញ្ញា
ទើបអ្នកសុខាគ្រប់ជាតិអើយ ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ១៣-កម្មជាអ្នកលិខិត
# មិនមែនព្រហ្មលិខិតទេ



ខ្ញុំសូមប្រគេននិងជូនបរិស័ទ
ហើយសូមប្រណិប័តន៍តាមផងណា
អស់អ្នកនិពន្ធក្មេងនិងកុមារ
និងអ្នកសិស្សាគ្រប់ប្រាណផង ។
អ្នកគ្រូលោកគ្រូនិងព្រះសង្ឃ
សូមតាំងចិត្តផ្ងង់ហើយកុំហ្មង
ឱ្យយល់ពាក្យ**ព្រហ្ម**ណាប្អូនបង
កុំឱ្យខុសឆ្គងតកូនចៅ ។
តែជាពិសេសអ្នកនិពន្ធ
វណ្ណៈគ្រប់ធនខ្ញុំទុកជាផៅ
ទើបជួយតម្រង់បន្តិចទៅ
ឱ្យមានទិសដៅមិនខុសតម្រា ។

ពាក្យថា**ព្រហ្ម**នេះគឺពាក្យកើន
**សេចក្តីច្រើន**គ្រប់ប្រការ
ដែលអ្នកបានធ្វើពេញចិន្តា
រហូតសុខាបាននិព្វាន ។
បានកើតជា**ព្រហ្ម**មិនក្រៅអី
នោះគឺប្រុសស្រីដែលមានញាណ
ដឹងខុសយល់ត្រូវមិនបំពាន
ប្រឹងបោះជំហានដើរផ្លូវប្រពៃ ។
សម្មាទិដ្ឋិនិងត្រិះរិះត្រូវ
សែនល្អពេកកូវផុតចង្រៃ
ទើបបាន**វា**ច្រើន**ន**អចិន្ត្រៃយ៍
ដូចកែវចរណៃក្នុងហត្ថា ។
**សេចក្តីចម្រើន**គឺពាក្យព្រហ្ម
អស់មាមីងមុំគ្រប់អត្តា
កុំយល់ច្រឡំទៀតអីណា

រួចកែចិន្តាទើបមិនឆ្គង ។
អ្នកកើតមកក្រមិនចេះមាន
រស់ទាំងស្រែកឃ្លានថែមមានហ្មង
គឺកម្មលិខិតដែលជាអ្នកចង
វិញជាចំណងចងនឹងលិខិត។
អ្វីនៅក្នុងលោកកម្មអ្នកចែង
ឱ្យអ្នកចំបែងរែងនឹងក្រំចិត្ត
ក៏មកពីកម្មជាអ្នកលិខិត
ហើយថែមសុក្រិដ្ឋមិនលម្អៀង ។
កម្មចាត់ចែង**ព្រហ្ម**តាមនាទី
ឱ្យស្ថិតមូលមីតាមលេខរៀង
ជាន់១ជាន់២ឱ្យបានទៀង
កម្មមិនលម្អៀងសោះឡើយណា ។
បានកើតមកមានឬក្រក្រី
ប្រុសឬមួយស្រីសុខឬទុក្ខា

គឺកម្មទាំងអស់បញ្ជាការ

ព្រហ្មគ្មានទេណាមកលិខិត ។

រៀបរាប់ប៉ុណ្ណេះសង្ឃឹមថា

មីងមាយាយតានឹងអស់មិត្ត

និងអ្នកនិពន្ធគ្រប់កម្រិត

សូមយល់ចូលចិត្តកែត្រង់នេះផង ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ១៤-ឆាឡិមិនដែលធ្វើនំ ឱ្យឆ្អិនល្អទាំងអស់ទេ



សូមក្រើនឱម៉ែផងទាំងឡាយ
ទាំងជិតនិងឆ្ងាយទាំងប្រុសស្រី
ដែលបង្កើតកូននិងថ្នមបី
បំពេញនាទីមិនបែរប្រាណ ។
កម្លោះក្រមុំស្រស់សង្ហា
សោភ័ណកាយាល្អប្រៀបបាន
ទេវបុត្តធីតានាសួគ៌ឋាន
ព្រោះលោកពីរប្រាណអ្នករក្សា ។
តែទាស់បន្តិចណាម៉ែឱ
ចិញ្ចឹមស្រស់ពៅតែកាយា
មិនបានចិញ្ចឹមនូវចិន្តា
ពេលមានស្នេហាច្រើនបង្គំ ។

ពុកម៉ែដោយច្រើនតែងវាចា
ពីដើមមកណាកូនមាសមុំ
ឪម៉ែចិញ្ចឹមរហូតធំ
ដូច្នេះឯងកុំតសម្តី ។
អាងខ្លួនជានាឡិអ្នកចាក់នំ
ទោះតូចឬធំឆ្អិនឆៅក្តី
បង្វៃរតាមចង់មិនគិតអ្វី
ទោះកូនប្រុសស្រីប្រឹងយ៉ាងណា ។
តែសូមយល់ផងកុំតាមចិត្ត
រុញច្រានជីវិតនាងសូន្យសង្ហារ
ឱ្យដល់ដៃព្រានឃ្លានន្លូវតណ្ហា
ចុងក្រោយទុក្ខានេត្រាទឹកភ្នែក ។
នាឡិចាក់នំមែនតែមិនដូចចិត្ត
ខ្លះឆៅមែនពិតកុំចម្លែក
ឆៅមិនមែននំកុំប្រកែក

គឺនាឡិល្អឯកបានជានំដៅ ។
យ៉ាងណាមាតាបិតាផងដែរ
សូមគិតរិះរេដល់ស្រីពៅ
កុំអាងមានគុណរុញកូនទៅ
វានឹងហ្មងសៅទាំងអ្នកនិងកូន ។
បើបានជានាឡិគួរចម្អិននំ
ឱ្យឆ្អិនទើបសមនឹងមិនសូន្យ
ហូបបានទាំងសងដូចជិះក្បូន
ម៉ែចម្លងកូនតាមនិស្ស័យគ្នា ។
សូមគិតឱ្យច្បាស់គ្រប់ឪម៉ែ
កុំគិតចង់កែកម្មនាវា
ពីដើមបែបណាឥឡូវដូចគ្នា
នឹងមិនក្រំគ្រាព្រោះយល់ហេតុផល។
រៀបរាប់ប៉ុណ្ណឹងណាទានណា
សូមលោកមេត្តាកុំក្តៅហល់

# កុំខឹងអក្ខរានាំអំពល់
# ទទួលលទ្ធផលទុក្ខតែខ្លួនឯង ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ១៥-អាចារ្យ៣ពួក

(បិដកលេខ ៤១ ទំព័រ ៥២)



ខ្ញុំសូមរឭកនឹកដល់គុណ
គឺបានដល់បុណ្យពីបុព្វេ
និងគុណឧបជ្ឈាយ៍ដែលខ្ញុំស្នេហ៍
និងគុណពុកម៉ែយាយតាផង ។
ឥឡូវខ្ញុំសូមរៀបចែងចារ
អំពីអាចារ្យល្អឥតហ្មង
មាន៣ប្រការយ៉ាងច្បាស់ច្បង
ញាតិមិត្តប្អូនបងសូមចាំណា ។
១-គឺអាចារ្យល្អប្រពៃ
អ្នកដល់ព្រះត្រៃកែវរតនា
ព្រះពុទ្ធព្រះធម៌សង្ឃថ្លៃថ្លា
នេះជាអាចារ្យមានគុណក្រៃ ។

អាចារ្យបែបនេះមានទីណា
គឺគុណមហាលើសចរណៃ
ទៅលើកូនសិស្សអចិន្ត្រៃយ៍
មិនមែនស្រមៃតែជាសច្ចា ។
២-គឺអាចារ្យដឹងធម្មា
បានឃើញមគ្គាដោយបញ្ញា
សច្ចៈទាំងបួនដ៏ថ្លៃថ្លា
នេះជាអាចារ្យដ៏ប្រណិត ។
៣-គឺអាចារ្យចេតោវិមុត្តិ
បញ្ញាវិមុត្តិសម្រេចក្នុងចិត្ត
មិនមានអាសវៈមារឧក្រិដ្ឋ
អាចារ្យនេះពិតហៅមហា ។
ព្រះពុទ្ធព្រះអង្គបានសម្តែង
ថាគុណជាក់ស្តែងគ្មានគុណណា
ប្រៀប្រដូចបាននឹងអាចារ្យ

ទាំងបីនេះណាទេប្រុសស្រី ។
មានឧបការៈហួសបរិយាយ
ទោះបីចំណាយរយឆ្នាំក្តី
ក៏គុណមិនអស់នឹងស្រដី
ទោះបីផែនដីរលាយយ៉ាងណា ។
ទោះក្រោកទទួលផ្គងអញ្ជលី
ធ្វើបែបណាក្តីលុះសូន្យសង្ខារ
ឬបច្ច័យ៤និងគ្រឿងបរិក្ខារ
ក៏គុណអាចារ្យមិនអស់ឡើយ ។
តែមានអាចារ្យ១ចំនួន
មិនបានធ្វើខ្លួនឱ្យល្អែល្អើយ
ដឹកនាំសិស្សខុសឥតដឹងត្រើយ
ទាំងឆ្លើយចម្លើយក៏ខុសតម្រា ។
គ្រូនេះគ្មានគុណបន្តិចឡើយ
នាំសិស្សខុសត្រើយឆ្ងាយសុខា

បានត្រឹមតែទុក្ខនិងឈឺផ្សា
ព្រោះអីអាចារ្យយល់ខុសសែនលង់។
សូមក្រើនដល់សិស្សផងនានា
គប្បីម្ដីម្នាកុំបីលិចលង់
កុំស៊ុនគំនិតពិតមិនឆុង
អ្នកនឹងមិនជុងក្នុងអវិជ្ជា ។
សង្ខេបប៉ុណ្ណោះឈប់វាចា
ខ្ញុំសង្ឃឹមថាអស់សិស្សគ្រប់គ្នា
នឹងបានយល់ជាក់មិនលីលា
អ្នករួចកំព្រាផុតក្ដីឆោត ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ១៦-មិនប្តូរនិស្ស័យចាស់



និស្ស័យធ្លាប់ធឹកនិងស្រវឹង
និស្ស័យធ្លាប់ខឹងមិនព្រមធ្លាស់
និស្ស័យជាចោរអាក្រក់ណាស់
និស្ស័យកម្មក្រាស់និងអកុសលា ។
និស្ស័យស្រីធិតមិនស្មោះប្តី
និស្ស័យកាកីពេញចិន្តា
និស្ស័យស្រីធឹកនូវសុរា
និស្ស័យខ្លោចផ្សាប្រឹងលេងប្តី ។
និស្ស័យមិនឡើងនិស្ស័យថោក
និស្ស័យចាញ់បោកប្រុសអប្រិយ៍
និស្ស័យប្តូរខ្លួនប្តូរនូវអ្វីៗ
និស្ស័យបានតីតែប្តីគេ ។
និស្ស័យសម្លាប់និងប្រហារ
និស្ស័យបាណាមិនចេះស្នេហ៍

និស្ស័យអាយុខ្លីតិចម្ល៉េះទេ
និស្ស័យមិនប្រែលុះអវសាន្ត ។
និស្ស័យអត់សីលទ្រុស្តនិងខ្លួន
និស្ស័យបំពួនដៀលអាត្មា
និស្ស័យនរកគ្មានជាតា
និស្ស័យទុក្ខាព្រោះមានវេរា ។
បើដឹងថាខ្លួននិស្ស័យយ៉ាងហ្នឹង
ម្តេចមិនខំប្រឹងស្វែងមគ្គា
ចម្រើនទានសីលនិងភាវនា
តែបែរនាំគ្នាចូលបាលេងស្រី ។
រីឯស្រីខ្លះត្រូវប្តីលេង
គិតតែចំបែងក្នុងជីវី
សោកាតឹងណែនចុកហ្ឫទ័យ
ខ្ញុំគ្មាននិស្ស័យបានចិត្តស្មោះឡើយ ។
ប្រុសខ្លះប្រពន្ធសូមលះលេង

កើតក្តីចំបែងចុកចាប់ពុំស្បើយ
យកស្រាជាមិត្តកន្ទេលខ្នើយ
ស្រែកថ្ងូររកត្រើយប្តឹងប្តល់ទេវតា ។
ស្រីប្តីត្រូវធិតប្រុសស្រីសូមលះ
ចម្រុងចម្រាសគ្មានមេត្តា
មិនប្តូរនិស្ស័យពីអាត្មា
តើសុខឯណាមកជិតបាន ។
ណ្តើយ!គួរគិរប្តូរនិស្ស័យ
អ្វីដែលនាំភ័យសូមគ្រប់ប្រាណ
តម្រង់តម្រូវធ្វើឱ្យបាន
នោះទើបក្សេមក្សាន្តដល់និព្វាន ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ១៧-សួរខ្លួនឯង និង ឆ្លើយខ្លួនឯង



សួរខ្លួនឯងថាចង់សុខទេ
បើទុក្ខឥតល្អែក្នុងជីវិត
ឆ្លើយខ្លួនឯងថាខ្ញុំត្រូវការពិត
ដូច្នេះប្រព្រឹត្តកុំបីខាន ។
អំពើសោភាទានាសីលា
វិរិយាមេត្តាក្នុងសន្តាន
កើបនូវអាក្រក់ត្រូវរុញច្រាន
ឱ្យចេញពីប្រាណទើបសុខា ។
សួរខ្លួនឯងថាចង់ចេះអត់
បើចង់មិនខ្សត់ត្រូវផ្ទៀងសោតា
ឆ្លើយខ្លួនឯងឡើងថាអ្នកណា
គឺត្រូវឧស្សាហ៍ស្តាប់នូវធម្មា ។
សេពគប់បណ្ឌិតអ្នកខ្ពង់ខ្ពស់
អ្នកមានកេរ្តិ៍ឈ្មោះលើភពពសុធា

មិនមានមាន:គ្មានឫក្សពារ
ទើបបានធូរធារកើនបញ្ញា ។
សួរខ្លួនឯងថាចង់ឈ្នះខ្លួនទេ
បើចាញ់ឆ្នាំខែចាញ់អត្តា
ឆ្លើយប្រាប់ខ្លួនឯងជាសមា
គឺចង់ណាស់ណាព្រោះលាយកិលេស។
រាគោទោសោនិងមោហា
ឥស្សាឥច្ឆាមកចាក់ស្រែះ
ចង់ឈ្នះពន់ពេកកុំប្រហែស
ទើបបានពិសេសឆ្ពោះបញ្ញាញាណ ។
ចិត្តអប់រំចិត្តដោយសតិ
អមសមាធិមិនបំពាន
ឥរិយាបថ៤ចិត្តកើនឈាន
កុសលជាស្ពានឆ្លងចិត្តសាន្ត ។
សួរខ្លួនឯងថាចង់ស្តាប់ធម៌ទេ

ចង់នៅទំនេរនិងសម្រាន្ត
ត្រូវឆ្លើយប្រាប់ខ្លួនកុំខកខាន
ផ្ចង់ចិត្តឱ្យបានស្តាប់ធម្មា ។
ព្រោះធម្មានេះជាធម៌ក្សាន្ត
ធ្វើខន្ធប៉ុន្មានិងនាមា
ផ្តាច់ចេញពីចិត្តឥតរួញរា
ធម៌ជានាវានាំកាន់ត្រើយ ។
សូមសួរខ្លួនឯងឆ្លើយខ្លួនឯង
ហេតុផលជាក់ស្តែងកុំកន្តើយ
កុំបមាទោណាអ្នកអ្នើយ
ជូនពរដល់ត្រើយនៃនិព្វានហោង

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ១៨-ស្ពឹចិត្ត



កាលកូនមាសស្នេហ៍នៅក្នុងផ្ទៃ
អ្នកម្តាយយកដៃថ្នមកល្បាណ
ស្ពឹចិត្តកូនម៉ែឈប់យំបាន
កូនសម្រាកប្រាណដោយសុខា ។
មាតាបិតាក៏ដូចគ្នា
កូនៗគ្រប់គ្នាលំទោនកាយា
ត្រូវយកចិត្តស្ពឹមាតាបិតា
ទើបគ្មានទុក្ខាសុខាបានជិត ។
ប្រុសស្រីបានស្នេហ៍គ្នានិងគ្នា
ស្ពឹចិត្តគ្រប់គ្រាដោយក្តីស្និទ្ធ
ពាក្យផ្អែមទឹកដមហួសបើគិត
ស្ពឹចិត្តនិងចិត្តទើបមានមង្គល ។
តាយាយក្មេងចាស់គ្រប់អង្គា
ក៏ត្រូវម្តីម្នានិងខ្វាយខ្វល់

យកធម៌ស្មុំចិត្តពិតមិនរសល់
និងឈប់អំពល់គ្រប់វេលា ។
យើងមានសតិស្មុំដួងចិត្ត
ហិរិល្អពិតមិនអាចគណនា
ស្មុំហើយស្មុំទៀតស្មុំពុំរា
ត្រាបាននាវាឡើងកាន់ធម្មយាន ។
ព្រះធម៌ជាច្បាប់ចងក្រងចិត្ត
ឱ្យធ្វើសុចរិតដោយស្រេកឃ្លាន
វិធីស្មុំចិត្តបែបនេះមាន
សារ័ករយលានបានដល់គោលដៅ ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ១៩-ស៊ូធ្វើជាទាសៈព្រះរតនៈត្រៃ



កើតមកជាមនុស្ស　　មិនគួរប្រទូស្ត
និងរតនៈត្រៃ　　បែរជាបែកចិត្ត
កាន់សាសន៍ដទៃ　　នោះពិតចង្រៃ
គ្មានទាំងជាតា ។
ប្រុសស្រីផងគ្នា　　ត្រូវលះវេរា
ចេញពីអាត្មា　　យល់គុណពុទ្ធា
និងធម៌ទេសនា　　ព្រះសង្ឃផងណា
ជាក្បួនជីវិត ។
កុំបីប្រហែស　　ចុះចាញ់កិលេស
ហ្នទ័យក្រៀមស្វិត　　លោភោទោសោ
មោហោកៀកកិត　　ច្បាស់ជាស៊ីយពិត
អស់ផ្លូវដោះស្រាយ ។
កុំយកអ្នកតា　　ឬក្រៅសាសនា
មកដាក់ជិតកាយ　　កាន់តែអ័ព្ទយស

ឈ្មោះនឹងស្អុយសាយ គ្រប់នាមនិកាយ
មិនមានខ្លឹមសារ ។
រាល់យើងគ្រប់គ្នា កើតមកក្រំគ្រោ
រស់ទាំងឈឺផ្សា បម្រើកិលេស
និងពួកតណ្ហា ប្រាសព្រាត់ឯកា
ក្នុងសង្សារទុក្ខ ។
ពពួកកិលេស ជាគ្រឿងឆ្អាបឆ្អេះ
ជាគ្រឿងស្មាញស្មុគ កើតក្នុងភពបី
ឥតមានក្តីសុខ មិនចេះស្រណុក
គ្រប់កាលវេលា ។
ល្មមភ្ញាក់ចិន្តា ហើយងើបអាត្មា
ចេញពីកម្មពៀរ បម្រើត្រៃរតន៍
នឹងផុតជរា កើតចាស់ឈឺជា
អស់ក្តីកង្វល់ ។

សំឡៀងកំណាព្យ

# ដោយសុិន អក្ខរា ព.ស.២៥៥៦



# ២0-ភ្លាត់និងបានពិតជានរក



រាល់ជីវិត បើមិនគិត ពិតជាស៊ប់
ចង់មិនបាន ជ្រុលជ្រួសខ្លួន ពិតមិនមួន
ទុក្ខសន្តាន ក្តៅអង្គប្រាណ បាបដុតចិត្ត ។
ភ្លាត់ពីបុណ្យ នឹងឃ្លាតគុណ ទុនត្រូវអស់
ពីជីវិត បានតែបាប វាលួនក្រាប
គុកឧក្រិដ្ឋ ព្រោះភ្លាត់ចិត្ត សាងអកុសល ។
ភ្លាត់ប្រហេស គុណពិសេស ចេះមិនដឹង
នឹងសោកសល គឺអវិជ្ជា នាំគ្រប់គ្នា
ជ្រួលច្របល់ នឹងអំពល់ ឥតបីស្រាន្ត ។
កុំធ្វើណា នាំខ្លោចផ្សា ចិន្តាស្អិត
ជាប់សាមាន្យ កុំស្នេហា ភ្ជាប់វាសនា
បាបរុញច្រាន អ្នកនឹងបាន ទុក្ខលាយភ័យ ។
ទាំងអ្នកមាន អ្នកអត់ឃ្លាន ហ៊ានបើតោង
អស់និស្ស័យ បុណ្យមិនជិត មានតែមិត្ត

| | | |
|---|---|---|
| បាបអាល័យ | ពេលអ្នកក្សัយ | អស់ទីពឹង ។ |
| ខ្ញុំរម្លឹក | សូមអ្នកនឹក | កុំបីស្ពឹក |
| រកពំនឹង | ក្សួនកុសលា | ជាវាសនា |
| ស្រស់ច្រឡឹង | ត្រូវខំប្រឹង | តទៅហោង ។ |

**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ២១-សមុទ្រសង្សារ



សមុទ្រល្វឹងល្វើយ គ្មានកោះឥតត្រើយ
ដាច់កន្ទុយភ្នែក រលកបក់បោក
តូចធំច្រើនប្លែក យើងគួរសង្វេគ
ដូចរឿងជីវិត ។
សត្វច្រើនពេកពន់ ពួកសត្វគ្រប់ធន
រស់នៅកៀកស្ថិត ពួកត្រីគ្រប់ភេទ
មករស់សណ្ឋិត ហើយសាងជីវិត
នៅក្នុងសាគរា ។
សមុទ្រសែនធំ ទឹកហូរលាយឡំ
នូវរាល់វេលា តាមទឹកភ្លៀងផង
ហូរចូលឥតរា សាយណ្តូទិវា
សមុទ្រឥតម្នេញ ។
យ៉ាងណាសង្សារ ធំហៅសែនមហា
ខ្វះមិនដែលពេញ ចិត្តស្វែងមិនឃើញ

ចិត្តខ្វល់រលេញ ទោះប្រឹងម្តេចមិញ
ក៏គេចមិនបាន ។
សង្សារៈទុក្ខ ច្រើនដោយក្តីស្មុគ
រកប្រៀបមិនបាន សត្តនិករ
រស់ទាំងប៉ុន្មាន ទុក្ខជាប់ចិត្តប្រាណ
នៅក្នុងសមុទ្រ ។
សមុទ្រតណ្ហា ដុតសត្វលោកា
ឱ្យក្តៅតក់ស្លុត រៀងរាល់យប់ថ្ងៃ
ខំតែមិនផុត នេះក៏សមុទ្រ
រាប់ចូលមួយដែរ ។
ម្យ៉ាងទៀតសង្សារ ពុំមាននរណា
អាចមកកែប្រែ ឱ្យជាយ៉ាងនេះ
ក៏មិនអាចបែរ ព្យាយាមឆ្នាំខែ
ក៏កែមិនបាន ។
អ្នកធ្លាប់ជាម៉ែ ជាពុកផងដែរ

ក៏ច្រើនហួសស្មាន ហួសគិតនឹងថ្លែង
ឱ្យសមមិនបាន ព្រោះច្រើនប្រមាណ
ដែលកើតវិលវល់ ។
ម៉ែមកកើតកូន ពេលសង្ហារសូន្យ
នឹងកម្មអំពល់ កូនកើតជាឪ
ព្រោះរឿងកម្មផល ដូច្នេះកុំឆ្ងល់
នាំក្តៅក្រហាយ ។
តាកើតជាចៅ ភ្ជាប់ជាញាតិផៅ
សុខទុក្ខសប្បាយ យាយកើតជាតា
ច្រើនហួសបរិយាយ គ្រប់សត្វរូបកាយ
វិលកើតជាក់ស្តែង ។
ធ្លាប់បៅដោះគ្នា គ្រប់ពេលវេលា
ជាតិមុនឥតក្លែង រស់នៅរួមគ្នា
ខ្លះបានប្រជែង រោគចិត្តចំបែង
ឈ្លោះហើយសាងពៀរ ។

ធ្លាប់ជាស្វាមី ប្រុសធ្លាប់ជាស្រី
កកើនកម្មកៀរ ស្រីកើតជាប្រុស
ហេតុផលសសៀរ រស់ខ្វះនាវា
ទ្រនំធម៌ថ្លៃ ។
ធ្លាប់កើតជាចោរ ធ្លាប់ជាប់មោហោ
ធ្លាប់មនុស្សចង្រៃ នៅក្នុងសង្សារ
រាប់អសង្ខេយ្យ ហួសក្តីស្រមៃ
មិនមែនសុបិន ។
ធ្លាប់គេកាត់ក្បាល វាសនាបណ្តាល
វិបាកដ៏ឆ្ពិន ឱ្យផលពិតជាក់
ទោះអ្នកខ្វាក់ខ្វិន សូមស្តាប់ព្រះសិន
ទើបអ្នកត្រូវបាន ។
កើតជាទេវតា ឆទេវលោកា
ភពបីប៉ុន្មាន កើតទៅជាព្រហ្ម
ស្ថិតនៅសុខសាន្ត គ្មានអ្វីប្រៀបបាន

ធ្លាប់កើតដូចគ្នា ។

អ្នកកើតជាខ្ញុំ រីឯរូបខ្ញុំ
ជាអ្នកពិតជា ខ្ញុំបៅដោះអ្នក
បៅខ្ញុំដូចគ្នា សូមគិតគ្រប់គ្រា

នេះសមុទ្រសង្សារ ។

ធ្លាប់កើតព្រះរាជា ហើយធ្លាប់ច្បាំងគ្នា
វេរាបញ្ញា ដណ្តើមទឹកដី
ប្រើរាជឱង្កា ថាត្រូវប្រហារ

ដើម្បីលាភី ។

ច្បាំងមិនចប់ឡើយ ទោះបីឈ្នះហើយ
ក៏ប្រឹងសម្តី រាជាទាំងសង
ក៏មានព្រះទ័យ ប្រាប់ពលគ្រប់ទី

ថាត្រូវប្រយុទ្ធ ។

ធ្លាប់កើតជាពាល និងធ្លាប់ដេកទ្រាល
ដូចព្យុះកំបុត ងងិតងងល់

លិតញាតិសុទ្ធៗ តែនៅមិនស្កុត
និងព្រាយអវិជ្ជា ។
កើតគោក្របី សត្វឈ្មោលនិងញី
ឆ្កែឆ្មាសត្វលា ជ្រូកមាន់ក្អែបខ្ចី
កណ្តុរសត្វទា បរិស័ទគ្រប់គ្នា
គិតហើយចាំផង ។
សង្ខេបប៉ុណ្ណោះ គ្រាន់ជាចំណេះ
សម្រាប់ប្អូនបង គិតកែចិត្តកោង
ខុសមកកន្លង សូមចប់មួហ្មង
ពីនេះទៅអើយ ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ២២-ដើមរស់ទើបផ្លែមាន



ដើមដូងដើមខ្នុរនិងដើមស្វាយ
យើងកុំគិតឆ្ងាយខាតវេលា
ចេញផ្លែចេញផ្កាដើមរស់គ្រប់គ្រា
មិត្តគ្រប់អង្គាគិតកុំសៅហ្មង ។
កូនមានជីវិតរស់ធំប្រាណ
សូមកុំនឹកស្មានគ្មានអ្នកទាំងសង
បើគ្មានលោកទេអ្នកទាំងប្អូនបង
គ្មានវាសនាផងឃើញព្រះអាទិត្យ ។
រីឯកូនសិស្សផងទាំងឡាយ
សូមអ្នកខ្វល់ខ្វាយនៅក្នុងចិត្ត
បើគ្មានគ្រូហើយវិជ្ជាអត់ពិត
តែព្រោះលោកគិតទើបអ្នកចេះបាន ។
កើតមកឧត្តមបានជាមនុស្ស
សូមកុំប្រទូសកើតកម្មសាមាន្យ

ព្រោះបុណ្យវាសនាចារចំណាន
ទើបទទួលបាននូវភាពថ្លាថ្លៃ ។
ទោះក្រទោះមានស្មុគទុក្ខា
ក៏ល្អអស្ចារ្យជាងកែវចរណៃ
បើក្រធ្វើបុណ្យសន្សំនិស្ស័យ
បានជាបច្ច័យផុតកម្មអប្រិយ៍ ។
បានកើតជាមនុស្សព្រោះបានដើមទុន
បានដល់ផលបុណ្យមានគុណឥតបើ
បើគ្មានដើមរស់គឺបុណ្យពិសី
អ្នកមិនបានអ្វីទៅជាតិថ្មីឡើយ ។
គ្រហស្ថបព្វជិតរាល់ព្រះអង្គា
គួរប្រឹងម្មីម្នានឹងកុំកន្តើយ
ថៃដើមរហូតលុះអ្នកដល់ត្រើយ
អ្នកនឹងជាស្បើយអស់រោគរាគា ។
នាំចិត្តរាប់បុណ្យសាងគុណជីវិត

ឱ្យបានប្រណិតនឹងបានសោភា
គេចរឿងក្លែងក្លាយនិងពៀរវេរា
ចិត្តសាមគ្គីគ្នាព្រោះសតិនៅ ។
សូមផ្តាំដល់មិត្តកើតចាស់ឈឺស្លាប់
មិត្តអើយប្រញាប់កុំសុញ្ញនាំសៅ
ដល់នៅត្រៃរតន៍បានជាសំពៅ
អ្នកនឹងបានទៅដល់ត្រើយសុខសាន្ត ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ២៣-អ្នកកាចខ្មុំស្លូត



អ្នកដែលកើតចិត្តប្រទូស្តរ៉ាយ
ជេរពុកខឹងម្តាយចម្រើនចិត្តកាង
ចង្រ្កានផ្ទះឯងឆេះដល់ជិតខាង
ខុសអីបានអាងអញចាស់ជាងឯង ។
ខឹងម្តាយវាយកូនជេរដល់ចៅ
ចិត្តកើតសោកសៅរមួលចំបែង
ស៊ីត្រីស្លាក់ឆ្អឹងថាគេជាក់ស្តែង
ស្លាក់ឆ្អឹងខ្លួនឯងបន្ទោសឆ្នាំបាយ ។
ជូនខ្លួនហែវឃ្លានខ្យល់កាយគ្រាំគ្រា
បន្ទោសម៉ែវាថាមិនខ្វល់ខ្វាយ
អញធ្វើការហត់ជេរដល់អ្នកម្តាយ
កាចនឹងប្រឹងស្តាយនូវចិត្តសាមាន្យ ។
សូមក្រើនអ្នកឆ្លាតនិងអ្នកអត់ធន់
អ្នកកុំរិះគន់នាំពៀរដល់ប្រាណ

ចក្ខុបញ្ញាស្រាវជ្រាវសន្តាន
ទើបអ្នកចាប់បាននូវធម៌កុសលា ។
អ្នកកាចខ្ញុំស្លូតខ្ញុំស្លូតអ្នកល្អ
ខ្ញុំរឹតបវរអ្នករឹតសុខា
ព្រោះខ្ញុំចម្រើននូវធម៌មេត្តា
ទើបអស់ទុក្ខារវាងទាំងសង ។
សង្ឃឹមបរិស័ទបព្វជិតគ្រហស្ថ
អ្នកនឹងរលាស់ចិត្តពាលយង់ឃ្នង
ដើរចេញពីកម្មទុយ៌សក្តីឆ្គង
ជូនបុណ្យថែមផងសូមអនុមោទនា ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ២៤-សត្វស្លាបសាងសំបុក



នាមយើងជាមនុស្សសូមគិតឱ្យឆ្អិន
នឹងសូមឱ្យបិននូវហេតុផលជិត
មានឡានវីឡាញាតិទាំងឆ្ងាយជិត
ស្រឡាញ់មូលមិត្តទិវាសាយណ្ហ ។
ប្រុសស្អាតស្រីស្រស់កម្លោះក្រមុំ
ថ្លៃថ្លាឧត្តមព្រោះបុណ្យគ្រប់គ្រាន់
មានលុយដុល្លារចង់អីបានទាន់
គ្មានអ្នកជិះជាន់ដូចអ្នកក្រក្រី ។
តែសូមកុំភ្លេចបើមានលុយឡាន
មាសប្រាក់ថ្កើនថ្កានខ្ញុំប្រុសខ្ញុំស្រី
ត្រូវធ្វើបុណ្យផងទាន់មានជីវី
អ្នកពិតសម្តីសោភាអស្ចារ្យ ។
ទុកការពារខ្លួននៅពេលជិតស្លាប់
ជាទ្រព្យចំណាប់នៅពេលមរណា

ហើរទៅឋានសួគ៌នឹងសោយសុខា
មា្ច៉ងទៀតអស្ចារ្យឆ្ងាយបាបអប្រិយ៍។
យើងមើលសត្វស្លាបទោះបីម្តេចម្តា
មានស្លាបយ៉ាងណាក៏ខំឥតបី
ខំធ្វើសំបុកជាផ្ទះសិរី
ជើងស្លាបម្តេចក្តីនៅសាងទីពឹង ។
ពាក្យសាងសំបុកសំដៅយកបុណ្យ
ព្រោះអីទ្រព្យធនដែលមានប៉ុណ្ណឹង
បើក្រៅពីបុណ្យគ្មានអ្វីលំនឹង
សេចក្តីប៉ុណ្ណឹងសង្ឃឹមញាតិយល់ ។
សូមឱ្យអស់មនុស្សជនទាំងប្រុសស្រី
ក្នុងក្តីចាស់ក្តីអ្នកត្រូវខ្វាយខ្វល់
សាងលំនៅស្ថានដោយបុណ្យនិមល
ដល់ព្រមមគ្គផលនៅទីបញ្ចប់ ។
សូមបុណ្យកុសលផងនានា

បានជានាវាសំណាងមានភ័ព្វ
ឱ្យបានសម្រេចគ្រប់វ័យស្រទាប់
កាន់សីលឱ្យជាប់ឱ្យទានកុំខាន ។
សូមឱ្យអ្នកជួបសប្បុរសបណ្ឌិត
ជាភូមិប្រាជ្ញពិតជួបព្រះទ្រង់ញាណ
ស្តាប់ធម៌បានជោគលោកុត្តរឈាន
នឹងបាននិព្វានកុំបីឃ្លាតឡើយ ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ២៥-ទុកកិត្តិយសឱ្យព្រះសង្ឃផង



មុននឹងរៀបរាប់ខ្ញុំសូមអភ័យ
បើទាស់និស្ស័យប្រណីមេត្តា
ណាបញ្ញាខ្ចីមិនខ្លាំងដូចខ្លា
ដូច្នេះករុណាឱ្យខ្ញុំមុនផង ។
កិច្ចមុនដំបូងសូមអ្នកនិពន្ធ
វណ្ណៈគ្រប់ធន់ដែលល្បីពុំឆ្គង
ប្រុសក្តីស្រីក្តីក្រោយមុនដៃរផង
សូមកែរឿងឆ្គងអ័ព្ទឱនសាសនា ។
និពន្ធនូវរឿងប្រលោមប្រឌិត
ចង់ល្បីពិតៗនៅក្នុងលោកា
បញ្ចេញបញ្ចូលតាមតែអាត្មា
មិនគិតសាសនារបស់ខ្លួនឡើយ ។
និពន្ធចម្រៀងមានន័យដូចគ្នា
យកពាក្យសង្ឃាបង្ហោះខុសត្រើយ

យកសង្ឃមកលេងមិនគិតសោះឡើយ
ឱ!អ្នកនិពន្ធអ្ហើយតើត្រូវដែរអើ ។
ខ្ញុំដឹងខ្ញុំយល់ពីចិត្តអ្នកចង់
ធ្វើឱ្យព្រះសង្ឃបានល្អឥតបី
កុំធ្វើបែបហ្នឹងខុសព្រះជិនស្រី
ដែលទ្រង់ពោលស្តីប្រដៅល្អបាន ។
ទូន្មានដោយធម៌មិនសម្អុយឈ្មោះ
ទ្រង់ឥតបន្ទោសសាវកអង្គប្រាណា
តែទ្រង់ករុណាសាវកប៉ុន្មាន
ឱ្យល្អសុខសាន្តនៅក្នុងភេទសង្ឃ ។
ដូច្នេះអស់លោកនិពន្ធទាំងឡាយ
មុននឹងបរិយាយពីចិត្តដែលចង់
លើសង្ឃមកលេងតាមចិត្តចំណង់
រែងគិតឱ្យគង់ណាកល្យាណ ។
សាសនាព្រះពុទ្ធមិនសម្រាប់លេង

ដែលដូចកូនក្មេងគ្រប់លំនៅស្ថាន
ជិះជាន់មិនគិតបាបបុណ្យប៉ុន្មាន
សូមគិតវិញថ្កានទាន់ខុសតិចតួច ។
ទោះលុយដុល្លារសំខាញ់ម្តេចក្តី
ឬឈ្មោះល្បាញល្បីខ្ពស់លើសភ្នំស្រួច
ប្រណីសាសនាកុំឱ្យសង្ឃខូច
អ្នកពិតនឹងរួចពីក្តីអំពល់ ។
បើគិតតែឈ្មោះមិនគិតសាសនា
នៅក្នុងខេមរាជាតិខ្មែរសោកសល់
ខូចអីខូចទៅចិត្តខ្ញុំមិនខ្វល់
ឱ្យតែបានដល់និងជោគលាភី ។
គំនិតបែបនេះមិនគាំទ្រឡើយ
ខុសហើយលើខុសហួសនឹងស្រដី
តែបើលោកកែគឺល្អគ្មានពីរ
ហើយនឹងជោគជ័យនូវកិច្ចការងារ ។

ចំណុចមួយទៀតគ្រប់រឿងនិពន្ធ
គំនិតមូលធនស្ថិតនៅគ្រប់គ្រា
គឺរឿងជំនឿលើទឹកគង្គា
ខុសពីភគវាដែលទ្រង់សម្តែង ។
មានរឿងខ្លះទៀតសង្ឃមិនពិត
បំបួសមិនគិតជាសង្ឃក្លាយក្លែង
ខុសច្បាប់វិន័យប្រាកដជាក់ស្តែង
យកតួកំប្លែងជំនួសសង្ឃពិត ។
ចំណុចគួរលោកយកសង្ឃដែលត្រូវ
បួសល្អពេកកូវច្បាស់វិន័យស្និទ្ធ
តែរកតែស្អាតអ្នកល្អប្រណិត
តើសង្ឃដែលពិតមិនល្អមែនទេ ។
មិនល្អតែត្រូវស្អាតតែវាខុស
រីឯពាក្យមនុស្សយល់ច្បាស់រឿងកេរ្តិ៍
មិនមែនព្រោះលាភលះសាសន៍ចោលទេ

គិតផងណាស្នេហ៍គិតយកមួយណា ។
អាគមឧមអាមមិនមែនរឿងច្បាស់
ជារឿងក្រឡាស់មិនត្រូវតម្រា
ទាំងអស់អ្នកបួសនៅក្នុងសាសនា
មិនគួរត្រូវការលះសាសនាឡើយ ។
សង្ខេបរឿងវ៉ាវនឹងពោលពាក្យត្រង់
សូមកុំយកសង្ឃទាំងពួងទាំងឡាយ
ដាក់រឿងប្រឌិតនាំសាសន៍នាយអាយ
គេនឹងមើលងាយថែមគ្មានតម្លៃ ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ២៦-កុំយុំខ្លួនឯងទុកក្លួងភពបី



ក្នុងទ្វីបលោកាពុំមានអ្វីពិត
សុទ្ធរឿងប្រឌិតបោកប្រាសប្រុសស្រី
សូម្បីតែសុខក៏សុខឥតន័យ
ធ្វើឱ្យប្រុសស្រីវិលវល់ចិន្តា ។
ទិដ្ឋិតណ្ហានិងឧបាទាន
រូបដល់វិញ្ញាណពិតគឺអនិច្ចា
ទុក្ខអើយសែនស្មុគនិងជាអនត្តា
រកតែខ្លឹមសារបន្តិចគ្មានឡើយ ។
កាមភពរូបភពនិងអរូបភព
មិនមែនសំណព្វសម្លាញ់កៀកកើយ
ធាតុពិតគឺមារនាំទុក្ខឥតស្បើយ
នឹងនាំដល់ត្រើយគឺទុក្ខបួនកង ។
បើនៅភពមនុស្សសែនទុក្ខលំបាក
បញ្ហាគ្មានស្រាកមានតែសៅហ្មង

ចួនឈ្លោះប្រកែករវាងប្អូនបង
ចួននិងអ្នកផងរកសុខមិនបាន ។
ចួនកូននិងម្តាយប្តីនិងប្រពន្ធ
រឿងរ៉ាវគ្រប់ធនយាយីសាមាន្យ
រឿងតូចនិងធំកើតឡើងពុំស្រាន្ត
ភពមនុស្សគឺបានតែទុក្ខខ្លោចផ្សា ។
ទោះមានលុយឡានចាយសឹងមិនអស់
តែជារបស់មិនមានខ្លឹមសារ
ថែមនាំវង្វេងក្នុងវដ្តសង្សារ
នេះហើយកាមាសម្រាប់ពួកមនុស្ស។
រីឯនទេវតាក៏គ្មានអ្វីគ្រាន់
តាមថ្នាក់និងជាន់កុំគិតយល់ខុស
សុទ្ធតែជាហេតុឱ្យទេពស្រីប្រុស
វិលកើតមិនខុសពីមនុស្សដូចគ្នា ។
ខ្ញុំសូមបញ្ចប់ត្រឹមតែប៉ុណ្ណោះ

សូមកុំប្រហែសតែគួរម្ដីម្ដា
គេចចេញឱ្យឆ្ងាយមិនត្រូវរួញរា
ទើបាបសុខជាផុតភពបីហោង ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ២៧-ទឹកភ្នែកអ្នកជម្ងឺ



កាលមិនទាន់ឈឺខ្លួននៅកម្លាំង
គ្មានឧបសគ្គរាំងរាឡើយណា
មានតែជោគជ័យរៀងរាល់កិច្ចការ
ស្រវឹងអាត្មាពេញមួយជីវិត ។
ស្រវឹងពេលយប់វង្វេងលុះថ្ងៃ
ប្រឹងរកកម្រៃប្រលោមកៀកកិត
ជួបជុំកូនចៅញាតិជៅឆ្ងាយជិត
មូលមីស្នេហ៍ស្និទ្ធគ្មានពេលស្រាកស្រាន្ត ។
មានលុយមានឡានិងផ្ទះវីឡា
រូបកាយសង្ហាឆើយឆាយហួសស្មាន
ញាតិក៏សម្បូរប្រុសស្រីគ្រប់ប្រាណ
វិលវល់សន្តានមិនខ្វល់រឿងបុណ្យ ។
ស្រឡាញ់ពេញចិត្តនឹងអ្វីដែលមាន
ភ្លេចអន្តរធាននិងរឿងស៊ីយស៊ុន

គិតតែរឿងទៀងភ្លេចនូវទារុណ
រត់គេចពីបុណ្យចម្រើនអកុសលា ។
ព្រោះហេតុតែទ្រព្យហ៊ានធ្វើអ្វីៗ
បៀតបៀនញាំញីកាប់វាយប្រហារ
ពិឃាតជីវិតឥតក្តីមេត្តា
ឱ្យគេខ្លោចផ្សាហួសនឹងបរិយាយ ។
៥០ឆ្នាំប្លាយបានកន្លងទៅ
ម៉ឺនសែនសោកសៅបានមកដល់កាយ
ប្រណាំងជីវិតនូវអ្នកទាំងឡាយ
លួចក្តីសប្បាយឱ្យទុក្ខអ្នកម្តង ។
ដល់ពេលខ្លួនឈឺទើបភ្ញាក់អាត្មា
ពេលឈឺកាយានិងក្តីមួហ្មង
ទឹកភ្នែកស្រក់ហូរមកច្រើនកន្លង
នឹកឃើញរឿងឆ្គងដែលធ្លាប់ប្រព្រឹត្ត ។
ចួនបានដឹងថាជម្ងឺដែលខ្លួន

កើតមកផ្ទួនៗនៅក្នុងជីវិត
ព្យាបាលមិនជាអស់សង្ឃឹមពិត
ទឹកភ្នែកស្នេហ៍ស្និទ្ធកៀកគ្រប់វេលា ។
កាលមិនទាន់ឈឺមិននឹកឃើញសង្ឃ
ឥឡូវចិត្តចង់ចំពោះសង្ឃា
និមន្តលោកមកគ្រាន់បានជាគ្នា
នឹងអារាធនាសូត្រធម៌ឱ្យស្តាប់ ។
អាងអីទឹកភ្នែកនិងរឿងឈឺចិត្ត
ឃើញកំហុសពិតមុនមិនប្រញាប់
ដល់ជិតហួសពេលទើបប្រឹងត្រងត្រាប់
ព្រោះខ្លួនជិតស្លាប់ចោលភពផែនដី ។
ស្រែកហៅកូនចៅលោកប្តីភរិយា
ថាអញរងាសូមអ្នកប្រណី
ជួយយកអាសាណាកូនប្រុសស្រី
ស្រណោះជីវិម៉ែឪនេះផង ។

ខ្លួនកាន់តែឈឺគ្មានក្តីស្រាកស្រាន្ត
សុខសួគ៌ប៉ុន្មានអត់បានវិញចង
មិនបានសាងទុកវារឹតតែឆ្គង
ឈឺចាប់មួហ្មងពិបាកជាងស្លាប់ ។
យប់ឡើងកាលណាបន់ទៅទេវតា
សូមលោកមេត្តារួសរាន់ប្រញាប់
សន្តោសអភ័យកុំខឹងយកត្រាប់
មិនចង់អួរអ័ព្ទពេលខ្ញុំមរណា ។
កាលគ្មានជម្ងឺអាងណាស់ទ្រព្យា
មិនស្គាល់វេទនានៅក្នុងជីវ៉ា
ម៉េចមិនយកទ្រព្យទុកជាវាសនា
ម៉េចហៅទេវតាឱ្យជួយធ្វើអី ។
នេះហើយពេលជិតតែនឹងមរណា
ទើបក្តីខ្លោចផ្សាបៀតបៀនឥតបី
ប្រញាប់រកព្រះសូមក្តីប្រណី

ព្រោះឥតមានអ្វីក្រៅពីបុណ្យឡើយ ។
ខ្ញុំអ្នកជម្ងឺសូមផ្តាំអ្នកជា
កុំបមាទាក្រែងទុក្ខមិនស្បើយ
ខ្លួនមិនទាន់ឈឺធ្វើល្អអ្នកអ្ហើយ
ធ្វើកុំល្មើលល្មើយលុះជីវិតក្ស័យ ។
មានក្តីក្រក្តីត្រូវតែឱ្យទាន
កុំបីបំពានត្រូវឱ្យអភ័យ
កុំសាងសត្រូវមេត្តាអាល័យ
បានជានិស្ស័យពូជពង្សបណ្ឌិត ។
ប្រឹងស្តាប់ធម៌អាថ៌គ្រប់ពេលវេលា
គួរយកធម្មាមកទុកក្នុងចិត្ត
យល់ពីសង្សារថាគុកឧក្រិដ្ឋ
ទើបបានសុខពិតអស់នូវបញ្ហា ។
ឱ្យតិចឱ្យច្រើនដល់អ្នកមានសីល
បំផ្លាញចិត្តខ្ជិលចេញពីឱវា

ទានសីលភាវនាទាំងនេះហើយណា
ទុកជាវាសនាចម្លងរកត្រើយ ។
កុំឱ្យដូចខ្ញុំបានតែទឹកភ្នែក
រស់ត្រឹមអល់អែកនិងក្តីស្តាយក្រោយ
ទឹកភ្នែកគ្រប់គ្រាព្រោះគ្មានអំណោយ
អស់មិត្តទាំងឡាយកុំធ្វើតាមខ្ញុំ ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ២៨-ទឹកភ្នែកអ្នកជិតស្លាប់



រស់នៅលើទ្រព្យភ្លេចគិតរឿងស្លាប់
មិនដែលឈឺចាប់បន្តិចណាឡើយ
ជាតិជរាព្យាធិមកជិតដល់ហើយ
មិនដឹងខ្លួនឡើយគិតតែសប្បាយ ។
ចាស់សក់ស្កូវព្រោងសដូចសំឡី
មិនព្រមដឹងក្តីនៅតែលេងកាយ
តាក់តែងរូបរាងមិនចេះនឿយណាយ
ដុល្លារច្រើនចាយចំណាយហូរហៃ ។
ស្រីស្រាកែវប៉ែងដឹកមុខជានិច្ច
នឹកមិនដែលភ្លេចទោះច្រើនឆ្នាំខែ
វីទាននិងសីលស្តាប់ធម៌ផងដែរ
នឹកមិនឃើញទេទោះនៅជិតវត្ត ។
ម្យ៉ាងគំនិតថាខ្លួនអញនៅក្មេង
កុំទាន់ចំបែងចាំដល់ជួរចត់

ចាំចាស់គ្រាំគ្រាធ្វើការអីហត់
ទើបអញចូលវត្តឱ្យទានសាងសីល ។
ភ្លេចហើយមែនទេថារឿងជីវិត
មិនទៀងមែនពិតតែចិត្តនៅខ្ជិល
ឬមិនចេះស្លាប់បានជានៅខិល
ដើរសាងមន្ទិលដល់ខ្លួនគេឯង ។
កុំយល់គិតថាមកពីមិនទៀង
ទើបមិនព្រមរាងនឹងមិនចំបែង
សប្បាយឱ្យហើយក្រោយចាំរអែង
ជីវិតដូចផ្សែងចាំគិតរឿងទាន ។
ដល់មានបញ្ហាមរណាមកដល់
កាយចិត្តខ្វាយខ្វល់ជិតបាត់វិញ្ញាណ
ធ្វើទានសំណល់ធ្វើចិត្តស្រែកឃ្លាន
ទោះលុយរាប់លានក៏គ្មានខ្លឹមសារ ។
ព្រោះចិត្តនៅស្តាយរឿងដែលកន្លង

មិនគួរនាំឆ្គងឱ្យឈឺចិន្តា
ជិតហួសពេលហើយធ្វើបានប៉ុណ្ណា
រីឯសង្ខារត្រូវសូន្យថ្ងៃស្អែក ។
យំស្តាយពន់ពេកដឹងថាគ្មានន័យ
តែចិត្តចង្រៃវានៅចង់ស្រែក
ថាមិនគួរសោះពេលត្រូវបែងចែក
ថ្ងៃនេះថ្ងៃស្អែកខ្ញុំត្រូវមរណា ។
ធ្វើទានមិនបានសាងសីលមិនកើត
មច្ចុជើងឆើតខិតជិតអាត្មា
ស្តាប់ធម៌លែងឮថ្លង់អស់សោតា
ជីវិតឯកាទាំងមិនទាន់ស្លាប់ ។
ទីពឹងទឹកភ្នែកមិនបានសួគ៌ា
បានតែក្រំគ្រានិងក្តីអួរអាប់
បើពឹងគេឯងគេបន់ឱ្យស្លាប់
ស្លាប់ឱ្យប្រញាប់វាជាងរស់នៅ ។

ទឹកភ្នែកនាំទុក្ខជិតនឹងមរណា
សូមផ្តាំយាយតាទាំងកូននិងចៅ
កុំដល់ចិត្តស្លាប់ទើបនាំញាតិជៅ
ធ្វើបុណ្យទុកទៅបរលោកនាយ ។
មុននឹងអ្នកស្លាប់ប្រញាប់ឱ្យទាន
ឱ្យតាមខ្លួនមានចិត្តចង់ចំណាយ
ឱ្យហើយឱ្យថែមកុំបីរសាយ
ទើបលែងខ្វល់ខ្វាយពេលយើងជិតស្លាប់ ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ២៩-ទឹកភ្នែកបំណុលកម្ម



បានកើតមកហើយទោះក្រទ្រព្យា
ប្រុសស្រីគ្រប់គ្នាកុំសាងពៀរអី
កុំខ្ចីមាសប្រាក់ជាប់កម្មអប្រិយ៍
ទឹកភ្នែកប្រុសស្រីហូរព្រោះបំណុល ។
បំណុលស្មើកម្មប្រចាំជីវិត
ដូច្នេះគួរគិតកុំឱ្យវាជ្រុល
បើមិនជំពាក់អ្នកកុំរវល់
អ្នកពិតមិនខ្វល់ទោះរស់ឬស្លាប់ ។
តែបើក្រហើយថែមមានបំណុល
នឹងជ្រួលច្របល់ប្រទះអ្ហរអាប់
ម្ចាស់អ្នកបំណុលប្រមាថចាក់កាប់
អ្នករស់ដូចស្លាប់ឈឺចាប់ហៅមហា ។
ទឹកភ្នែកព្រឹកល្ងាចគ្មានអ្នកអាល័យ
នេះជានិស្ស័យនៃអកុសលា

បាបកម្មទុយ៌សកោងកាចឫស្យា
អស់ហើយសុខាមានតែទុក្ខព្រួយ ។
ទោះមានបងប្អូនរួមនិងឪម៉ែ
គ្មានអ្នកជួយទេលែងមានជំនួយ
សូម្បីទេវតាក៏អត់មកស្ងួយ
មានតែខ្លួនមួយប្រឹងជួយអាត្មា ។
មិនទាន់បានសងត្រូវគេមកទារ
ទឹកភ្នែកក្រំគ្រោចេញពីឱរា
ទោះគេមើលងាយថាដៀលបៃបណា
ឱ្យដួងនេត្រាជួយបញ្ចេញទុក្ខ ។
ខំធ្វើការងារដោះបំណុលគេ
មិនហ៊ានទំនេរទោះបីស្មាញស្មុគ
លំបាកងងុយមិនហ៊ានសំកុក
នៅមិនស្រណុកព្រោះបំណុកកម្ម ។
ខ្លះឃ្លាតស្រុកទេសមាតាបិតា

ក្លាយជាឯការស់ទាំងប្រេះស្រាំ
នេះព្រោះតែអ្វីព្រោះបំណុកកម្ម
ព្រាត់ច្រើនខែឆ្នាំព្រោះកម្មរុញច្រាន ។
បែកម៉ែកូនចៅអ្នកដែលស្រឡាញ់
ព្រោះតែសំណាញ់អកុសលសាមាន្យ
ក្រៀកចងជីវិតរកសុខមិនបាន
គ្មានទេសុខសាន្តបានតែអប្រិយ៍ ។
បំណុលនៃកម្មបំណុលទ្រព្យា
ពិតនាំវេរានិងពៀរឥតបី
នាំអ្នកទឹកភ្នែកកណ្តាលរាត្រី
រហូតប្រុសស្រីសងបំណុលបាន ។
ដូច្នេះកុំលេងកុំលអាត្មា
ប្រយ័ត្នខ្លោចផ្សាវិយោគពុំស្រាន្ត
ក្រចុះកុំខ្ជីស៊ូលំប្រាណ
បានប្រាក់ប៉ុន្មានចាយតាមការគិត ។

នាំកូនប្រពន្ធមាតាបិតា
ឱ្យទានសីលាបញ្ញាប្រណិត
លះបំណុលកម្មសាងល្អសុក្រិដ្ឋ
ចុងក្រោយជីវិតផុតបំណុលកម្ម ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៣០-គុណឪពុក



គុណសម្បត្តិពុកមិនមែនថាគ្មាន
គុណពុករាប់លានរៀបរាប់មិនអស់
គុណពុកមិនតិចដៃលលោកតែងស្មោះ
គុណល្អឥតខ្ចោះលើកូនពិសី។
គុណសម្បត្តិពុកសែនល្អអស្ចារ្យ
គុណពុកនេះណាសែនល្អគ្មានពីរ
គុណពុកមាននៅក្នុងលោកទាំងបី
គុណពុកសោភីគ្មានជនប្រៀបបាន។
គុណសម្បត្តិពុកល្អជាងរតនៈ
គុណពុកតែម្នាក់ជួយកូនគ្រប់ប្រាណ
គុណពុកនៅស្ថិតក្នុងចិត្តសន្តាន
គុណពុកកល្យាណល្អលើសសួនច្បារ។
គុណសម្បត្តិពុកគ្របលើជីវី
គុណពុកចរណៃចេញជាផ្លែផ្កា

# គុណពុកជាស្រែឬជាជលសា
# គុណពុកជីវ៉ាមិនចេះរីងស្ងួត។



**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ៣១-ពុក...



ពុកកូនអើយ៉ាសែននឿយហត់
ពុកមានអំណត់អើយ៉ារាល់ថ្ងៃ
ពុកស៊ូអើយ៉ាទោះក្រំដួងចៃ
ពុកនៅប្រណីអើយ៉ាដល់កូន។
ពុកកូនអើយ៉ាលោកដូចជាម្លប់
ពុកឥតធុញថប់អើយ៉ានិងស្ងួន
ពុកផ្តល់ត្រជាក់អើយ៉ាសុខផ្ងួន
ពុកគឺជាក្បួនអើយ៉ាចម្លងបុត្រ។
ពុកកូនអើយ៉ាប្រៀបដូចផែនដី
ពុកផ្តល់ជីវីអើយ៉ាចិត្តមុត
ពុកស្មោះនិងកូនអើយ៉ាយ៉ាងសុទ្ធ
ពុកមិនរលត់អើយ៉ាស្នេហា។
ពុកកូនអើយ៉ាពុកថ្នាក់បមបី

ពុកយកជីវីអើយវ៉ាសង្ហារ
ពុកស៊ូផ្តាច់ប្តូរអើយវ៉ាមរណា
ពុកមិនពោលថាអើយវ៉ាតួញតែរ។
ពុកកូនអើយវ៉ាបានបង្ហូរឈាម
ពុកមិនដែលទាមអើយវ៉ាវិញទេ
ពុកស៊ូលះបង់អើយវ៉ារាប់ខែ
ពុកឥតទារទេអើយវ៉ាសំណង។
ពុកកូនអើយវ៉ាបង្ហូតញើស
ពុកគឺជាមនុស្សអើយវ៉ាគ្មានហ្មង
ពុកតែងធ្វើល្អអើយវ៉ាតបស្នង
ពុកឥតបែរខ្នងអើយវ៉ាឈប់ស្នេហ៍។
ពុកកូនអើយវ៉ាស៊ូបៀមក្តីទុក្ខ
ពុកប្តូរយកសុខអើយវ៉ាជាកេរ្តិ៍
ពុកទុកឲ្យកូនអើយវ៉ាមាសមេ
ពុករស់ព្រោះតែអើយវ៉ាកូនថ្លៃ។

ពុកកូនអើយវ៉ាស៊ូនៅហាលក្តៅ
ពុកមិនមួម៉ៅអើយវ៉ាហ្ឫទ័យ
ពុកទ្រាំគ្រប់យ៉ាងអើយវ៉ាឥតបី
ពុកទ្រាំលុះក្ស័យអើយវ៉ាព្រោះកូន។
ពុកកូនអើយវ៉ាកូនសូមអញ្ជលី
ពុកសូមប្រណីអើយវ៉ាដល់កូន
ពុកគឺជាព្រះអើយវ៉ាជាក្បួន
ពុកនាំរូបកូនអើយវ៉ាឲ្យត្រូវ។
ពុកកូនអើយវ៉ាសូមលោកទទួល
ពុកស្រស់និមលអើយវ៉ាពេកកូវ
ពុកសូមយកបុណ្យអើយវ៉ាដូចផ្លូវ
នាំឲ្យពុកទៅអើយវ៉ាសុខហោង។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ៣២-ត្រូវគិតពីដួងចិត្តឪពុក



ដួងចិត្តឪពុកសែនល្អប្រិមប្រិយ៍
ព្រោះពុកអភ័យដល់កូនគ្រប់គ្នា
ដួងចិត្តឪពុកប្រៀបដូចព្រហ្មា
ពុកមិនក្រំគ្រោទោះកូនធ្វើខុស។
ដួងចិត្តឪពុកជាម្លប់ត្រជាក់
ពុកខំឥតអាក់ទេណាមាសស្រស់
ដួងចិត្តឪពុកបរិសុទ្ធគ្មានទាស់
ពុកជាត្រើយកោះសម្រាប់តែកូន។
ដួងចិត្តឪពុកប្រៀបដូចជាទឹក
ពុកតែងតែនឹករកកូនមាសស្ងួន
ដួងចិត្តឪពុកតែងតែមាំមួន
ពុកនឹកដល់កូនគ្មានពេលរសាយ។
ដួងចិត្តឪពុកប្រៀបបានជាម្លប់
ពុកឥតបីថប់ឲ្យកូនជ្រកកាយ

ដួងចិត្តឪពុកគ្មានទេជិនណាយ
ពុកតែងខ្វល់ខ្វាយពីកូនគ្រប់គ្នា។

❀❀❀

# ដោយសុិន អក្ខរា ព.ស.២៥៥៦



# កូនសំណព្វចិត្តពុក



ពុកប្តូរជីវិតដើម្បីមាសថ្លៃ
រហូតសព្វថ្ងៃពុកឥតរាថយ
ទោះបីឧបសគ្គអ្វីណាក៏ដោយ
ពុកមិនបណ្តោយតាមវាសនាទេ។
កូនសំណព្វពុកស្មើសង្វារ
ពុកសែនស្នេហានិងកូនមាសស្នេហ៍
សង្វារពុកនេះមិនស្មើកូនទេ
ឯកូនមាសស្នេហ៍ពុកសែនពេញចិត្ត។
កូនសំណព្វពុកចូរកូនស្តាប់
រួចហើយចូរគ្រាប់តាមពុកមាសស្និទ្ធ
កូនត្រូវធ្វើល្អទើបគេពេញចិត្ត
ប្រព្រឹត្តិសុចរិតទើបពូជថ្លៃថ្លា។
ពុកសូមឲ្យកូនក្លាយជាកូនល្អ
កូនកុំគ្រាច់ចរធ្វើអកុសលា

# រៀរចាកផ្លូវចោកបើជាមនុស្សា
# បុត្រីបុត្រាកុំភ្លេចឡើយហោង។



**ដោយសុិន អក្ខរា ព.ស.២៥៥៦**



*រៀបរៀងដោយសាមណេរ* **១០៥** **ខន្តិសារោ សុិន អក្ខរា ព.ស.២៥៥៦**

# ៣៣-អាយុកប់ក្រោមធរណី តែពុកនៅឯឹកកូន



ពេលពុកនៅរស់ពុកថែកូន
រក្សាគ្រងស្ងួនពេញចិន្តា
គាំពារព្រលឹងផ្ចាល់ហត្ថា
អភិរក្សាគ្មានរសាយ។
មានទុក្ខជួបក្តៅក្តីសោកា
ក៏ពុកនេះណាត្រៀមអង្គកាយ
តស៊ូជូសកូនគ្មានជិនណាយ
ដួងចិត្តស្រស់ស្រាយកូនសុខា។
ឪពុកបារម្ភតាំងពីរស់
ក្រែងកូនមាសគ្រោះថ្នាក់ម្តេចម្តារ
ទុក្ខព្រួយយប់ថ្ងៃគ្មានពេលណា
ទំនេរអាត្មាឡើយពិសី។

ដល់ស្លាប់ទៅហើយនៅស្រណោះ
អាល័យអាលោះកូនប្រុសស្រី
ទោះខ្លួនស្លាប់ទៅកប់ក្រោមធរណី
ពុកនៅបេតីកូនរហូត។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៣៤-កុំបន្ទោសឪ



កុំបន្ទោសឪពេលពុកខុស
អាណិតសន្តោសគួរប្រណី
កុំបន្ទោសឪណាប្រុសស្រី
អាណិតលកលៃសាងនូវគុណ។
កុំបន្ទោសឪពេលពុកថា
អាណិតផងណាគួរទោរទន់
កុំបន្ទោសឪពាក្យធ្ងន់ៗ
អាណិតបន្ទាន់គោរពបូជា។
កុំបន្ទោសឪពេលពុកប្រើ
អាណិតកុំដើរពេលនិទ្រា
កុំបន្ទោសឪគួរម្ដីម្នា
អាណិតពុះពារធ្វើតាមពុក។
កុំបន្ទោសឪធ្វើទៅណា
អាណិតមេត្តាកុំសាងទុក្ខ

កុំបន្ទោសឪការងារនៅមុខ
អាណិតសាងសុខស្នងបិតា។
កុំបន្ទោសឪថាអប្រិយ៍
អាណិតដួងចៃគួរស្នេហា
កុំបន្ទោសឪថាឫស្យា
អាណិតជីវាធ្លាប់បមបី។
កុំបន្ទោសឪថាគ្មានគុណ
អាណិតតូចតន់មានអភ័យ
កុំបន្ទោសឪថាក្រក្រី
អាណិតគិតថ្មីឲ្យថ្លៃថ្លា។
កុំបន្ទោសឪក្រែងសាបសូន្យ
អាណិតសូមកូនគ្រប់អាត្មា
កុំបន្ទោសឪទៀតអីណា
អាណិតបិតាធ្លាប់ប្រទ្បែង។
កុំបន្ទោសឪនាំវិនាស

អាណិតគួរចៀសកុំវង្វែង

កុំបន្ទោសឪឈប់ចំបែង

អាណិតលីសែងគាត់ទៅវត្ត។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៣៥-ស្តាប់ពុកផងណាកូន



ទូន្មានព្រឹកល្ងាចពុកឥតខ្ជិល
ពុកខ្លាចកូនខិលកេរ្តិ៍អាស្រូវ
មានឈ្មោះស្អុយសាយដក់ជាប់នៅ
បានជាពុកត្រូវខំវាចា។
ប្រាប់ឲ្យខំរៀនសាងសុចរិត
កុំបោកប្រាស់មិត្តគេឈឺផ្សា
គេនឹងស្អប់កូនតាមប្រហារ
ឲ្យសូន្យសង្ហារចោលឪពុក។
គោរពចាស់ទុំជុំវិញខ្លួន
កុំបីគុំកួនកូនបានសុខ
លំឱនកាយចិត្តទោះក្រោយមុខ
មិនសាងក្តីទុក្ខគ្មានរវើរវា។
ចាស់ទុំសរសើរឲ្យតម្លៃ
ពេលកូនចរណៃចេះវន្ទា

គេទុកក្នុងចិត្តគ្រប់វេលា
ព្រោះតែឫកពារកូនប្រពៃ។
សុចរិតក្នុងខ្លួនមានប្រចាំ
ទោះច្រើនខែឆ្នាំសូមប្រុសស្រី
អនុវត្តន៍ឲ្យបានណាកូនថ្លៃ
ពុកមិនសូមអ្វីក្រៅពីនេះ។
បើកូនធ្វើបានពុកសប្បាយ
ទោះគ្មានប្រាក់ចាយមិនពិសេស
សំខាន់គឺកូនធ្វើបានប៉ុណ្ណោះ
ទុកជាជំនិះកូនជូនពុក។
ស្តាប់ពុកផងកូនកុំទទឹង
ពុកសូមប៉ុណ្ណឹងកុំកើតទុក្ខ
កុំទាន់ដើរចេញអាណិតពុក
វាមិនជាប់គុកពេលស្តាប់ហើយ។
បើកូនយល់តាមពាក្យខាងលើ

ពុកឥតសើរើទេកូនអើយ
មរណាពេលណាអស់ចិត្តហើយ
សូមកុំកន្តើយស្តាប់ពុកផងកូន។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ៣៦-កុំទុកពុកជា...តែគួរ...



កុំទុកពុកជាជនអប្រិយ៍
តែគួរពិសីគិតមើលផង
កុំទុកពុកជាគ្រឿងចម្លង
តែគួរនួនល្អងពិចារណា។
កុំទុកពុកជាជនគម្រក់
តែគួរកុំលក់នូវកុសលា
កុំទុកពុកជាជនឫស្សា
តែគួរជីវ៉ាឱនសិរសី។
កុំទុកពុកជាលាមកណា
តែគួរកន្ទិដ្ឋាប្រណម្យដៃ
កុំទុកពុកជាជនដទៃ
តែគួរកូនថ្លៃទុកដូចផ្កា។
កុំទុកពុកជារបស់ស្អុយ
តែគួរអង្គុយវន្ទកាយា

កុំទុកពុកជាជនចិត្តខ្លា
តែគួរបុត្រាវន្ទាថ្វាយ។
កុំទុកពុកជាជនកោងកាច
តែគួរខ្លបខ្លាចស្រីឆោមឆាយ
កុំទុកពុកជាជនចម្ងាយ
តែគួរខ្វល់ខ្វាយទទួលលោក។
កុំទុកពុកជាមនុស្សពាល
តែគួរកុំរាលត្រូវចូលរក
កុំទុកពុកជាជនស្មោកគ្រោក
តែគួរពន្លកគិតថាល្អ។
កុំទុកពុកជាអ្នកក្បត់កូន
តែគួរមាសស្ងួនមានចិត្ត-ស
កុំទុកពុកជាជនក្រីក្រ
តែគួរកូនល្អយល់ថាមាន។
កុំទុកពុកជាសត្វតិរច្ឆាន

តែគួរគ្រប់ប្រាណកសាងស្ពាន
កុំទុកពុកជាជនអន្តរធាន
កូនបាននិព្វានព្រោះពុកហោង។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ៣៧-អាសូរពុកខ្ញុំ...ពុកខំ...



អាសូរពុកខ្ញុំក្រៀមក្រំចិត្ត
ពុកតែងអាណិតនឹងប្រទាន
អាសូរពុកខ្ញុំខំទូន្មាន
ពុកខំបំពានធ្វើបាបព្រោះកូន។
អាសូរពុកខ្ញុំខំឥតស្រាក
ពុកឥតសម្រាកនាមជាក្បួន
អាសូរពុកខ្ញុំខំស្ទើរសូន្យ
ពុកប្រឹងវាលួនមិនខ្លាចកម្ម។
អាសូរពុកខ្ញុំជួបកម្មក្រាស់
ពុកប្រឹងប្រែងណាស់ចិត្តប្រេះស្រាំ
អាសូរពុកខ្ញុំមច្ចុំចំណាំ
ពុកនៅតែផ្តាំប្រាប់ប្រុសស្រី។
អាសូរពុកខ្ញុំពុំដែលណាយ
ពុកលំបាកកាយចិត្តរឹងរៃ

អាសូរពុកខ្ញុំខំអភ័យ
ពុកតែងប្រណីកូនគ្រប់គ្នា។
អាសូរពុកខ្ញុំលេបថ្នាគ្រោះ
ពុកនៅស្រណោះទោះវេទនា
អាសូរពុកខ្ញុំពុំគិតវេរា
ពុកស្រាយពៀរកូនចងខ្លួនឯង។
អាសូរពុកខ្ញុំលួនលើភ្លើង
ពុកខំងើបឡើងយ៉ាងរអែង
អាសូរពុកខ្ញុំយ៉ាប់តែឯង
ពុកខំឥតលែងឲ្យតែកូនរស់។
អាសូរពុកខ្ញុំមួយជីវិត
ពុកពុំដែលគិតព្រោះតែកូនស្រស់
អាសូរពុកខ្ញុំពុំស្រណោះ
ពុកនាំកូនប្រុសស្រីរកត្រើយ។
អាសូរពុកខ្ញុំឲ្យកូនសុខ

ពុកស៊ូត្រាំទុក្ខឲ្យកូនកើយ
អាសូរពុកខ្ញុំប្រៀបបានខ្នើយ
ពុកឲ្យកូនកើយរួចហើយលាកូន។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ៣៩-ស្អាតខ្លួនយើង បានល្អដល់អ្នកដទៃ



សូមក្រើនដល់អ្នកអប់រំទាំងឡាយ
មុនប្រដៅកាយចិត្តអ្នកដទៃ
ទូន្មានខ្លួនមុនទើបវាប្រពៃ
ដូចកែវចរណៃដែលនៅក្នុងខ្លួន ។
ប្រឹងប្រែងប្រព្រឹត្តរៀងរាល់យប់ថ្ងៃ
កុំសន្សំចៃប្រឹងឱ្យមុតមួន
សន្សំធម៌ល្អកុំបីគុំកួន
ត្រូងយោងយិតខ្លួនត្រូវតឿនអាត្មា ។
តាំងខ្លួនក្នុងសីលជានិរន្តរ៍
មិនត្រូវភាន់ស្លន់ខ្វះនូវបញ្ញា

មានទានបរិសុទ្ធនៅក្នុងចិន្តា
រលឹកអាត្មាសតិតាំងនៅ ។
ពេលខ្លួនបានល្អចិត្តគ្មានសៅហ្មង
ញាតិទេវតាផងសប្បុរសញាតិផៅ
ស្រឡាញ់ចូលចិត្តដូចកូននិងចៅ
ទោះបីអ្នកទៅទីណាក៏ថែ ។
បន្ទាប់មកទៀតទូន្មានគេឯង
កុំឱ្យចំបែងត្រូវពោលពាក្យស្នេហ៍
ណែនាំបែបណាយើងត្រូវធ្វើដែរ
នេះជាមន្តស្នេហ៍របស់ព្រះពុទ្ធ ។
បើធ្វើបែបនេះបានរួចបញ្ហា
លែងចុកពើតផ្សាឈប់ចិត្តស្រយុត
ព្រោះខ្លួនស្អាតស្អំគ្មានខុសមកមុត

ព្រោះវង្សព្រះពុទ្ធធ្វើបែបនេះណា ។

ទូន្មានឱ្យគេគ្រប់គ្នាមានសីល

អ្នកត្រូវកុំខ្ជិលតែត្រូវឧស្សាហ៍

តាំងខ្លួនក្នុងសីលដូចយើងបានថា

នេះជាតម្រាច្បាប់ទូន្មានគេ ។

ទូន្មានប្រាប់គេឱ្យលះកិលេស

ប្រាប់យ៉ាងវិសេសឥតស្រាកស្រាន្តទេ

ដូច្នេះត្រូវលះកិលេសទាំងទ្វេ

ខ្លួនយើងនិងគេត្រូវលះទាំងពីរ ។

សូមអស់បរិស័ទដែលកាន់សាសនា

ត្រូវយល់ដីកានៃព្រះមុនី

ត្រង់ថាខ្លួនឯងពិបាកសម្តី

ទូន្មានម្តេចក្តីនៅតែសាមាន្យ ។

ខ្លួនឯងនេះហើយពិបាកទូន្មាន
ជាងជនរាប់លានដែលយើងប្រាប់ប្រាណ
ខិលខូចជាងស្វាជាងសត្វតិរច្ឆាន
យើងទាំងប៉ុន្មានត្រូវប្រយ័ត្នផង ។
បើយើងបានល្អស្អាតអ្នកដទៃ
ជាប្រពៃណីរឿងដែលឥតហ្មង
ល្អកាយវាចារួមចិត្តនេះផង
ផ្សាយដល់ប្អូនបងសុខទាំងសងអើយ ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៤០-សម្បត្តិរបស់ចិត្ត



ជនដែលកើតមកអប្បប្រាជ្ញា
ច្រើនតែប្រាថ្នាប្រមូលទ្រព្យា
ជាសម្បត្តិខ្លួនទុកជាប់អង្គា
ទើបមិនវេទនាអស់ក្តីមួហ្មង ។
រស់កាប់ចាក់គ្នាដោយសម្តី
ទាំងប្រុសនិងស្រីប្អូននិងបង
មិនដឹងខ្លួនទៀតប្រាក់នាំឆ្គង
ឈ្លោះមុខក្រោយខ្នងព្រោះដុល្លារ ។
ស្រីចងពៀរប្រុសប្រពន្ធផិតប្តី
ព្រោះគំនិតខ្លីឥតយល់ការ
ក្បត់ប្តីប្រពន្ធប្រើហិង្សា
ព្រោះមិនរក្សាក្តីសន្តោស ។

កើតមកបើក្រមិនសុខចិត្ត
សាងកម្មឧក្រិដ្ឋជាប់កំហុស
ខុសច្បាប់ឃ្លាតធម៌ខូចពូជមនុស្ស
គិតតែប្រទុស្តឱ្យតែបាន ។
ឱ!អ្នកមានបាននិងក្រក្រី
សូមអ្នកប្រណីអាសូរសន្តាន
លះក្តីល្មោភចេញពីអង្គប្រាណ
អ្វីដែលមិនបានស្របតាមណា ។
រួចហើយយើងត្រូវប្រតិបត្តិ
សម្រួលដួងចិត្តដោយបញ្ញា
សាងសម្បត្តិចិត្តទៅអនា-
គតនោះថ្លៃថ្លាហួសពណ៌នា ។
១-គឺសទ្ធាជាសម្បត្តិចិត្ត

សែនល្អប្រណិតគួរគ្រប់គ្នា

សន្សំឱ្យត្រូវជឿឱ្យជា

អ្នកលែងក្រំគ្រោពេលខុសឆ្គង ។

២-បានដល់សីលដូចអលង្ការ

សម្បត្តិចិន្តាត្រូវអស់ប្អូនបង

រក្សារហូតកុំកន្លង

សម្បត្តិមនុស្សផងព្រោះសីលា ។

៣-គឺបានដល់នូវព្រះពុទ្ធ

និងព្រះធម៌សុទ្ធដ៏ល្អថ្លា

ព្រមទាំងព្រះសង្ឃក្នុងសាសនា

ដែលព្រះសាស្តាត្រាស់ថាស្រែបុណ្យ ។

៤-គឺបញ្ញាផុតចាកងងឹត

បំភ្លឺពិតៗដល់សត្វគ្រប់ធន

ឱ្យឃើញនូវត្រើយល្អពេកពន់

នេះចាត់ជាគុណសម្បត្តិចិត្ត ។

សង្ខេបប៉ុណ្ណោះព្រោះច្រើនណាស់

សូមកុំក្រឡាស់ណាអស់មិត្ត

ពិចារណារក្សាឱ្យស្ថិត

នូវសម្បត្តិចិត្តលុះអវសាន្ត ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ៤១-ស្រណោះព្រះរស់ អាសូរព្រលឺងម៉ែ



ប្រណីរូបម៉ែបើកូនចេះដឹង
សូមកុំរឹងត្អឹងណាពៅជីវ៉ា
ទាន់ម៉ែនៅរស់ឃើញពៅកន្ទិដ្ឋា
ទាំងភ្នែកមាតាឃើញកូនទាំងសង ។
នឹកឃើញគ្រាដើមម៉ែធ្លាប់ឱ្យបៅ
ឱ្យកូនមាសឆ្អៅស្រូបរសគ្មានហ្មង
ទោះម៉ែធ្វើការម៉ែនៅត្រងកង
ថ្នមកូននួនល្អងគ្រប់ពេលវេលា ។
ឥឡូវកូនធំម៉ែកាន់តែចាស់
ចិត្តកាយក្រឡះព្រោះម្តាយជរា

ស្រណោះព្រះរស់ណាកូនសោភា
ជួយឱ្យម៉ែជាផងណាឆោមឆាយ ។
ឥឡូវម៉ែស្លាប់បាត់សូន្យជីវី
តែកូនសម្តីទោះម្តាយឃ្លាតកាយ
អាសូរព្រលឹងម៉ែកូនកុំណាយ
បូជាលើកថ្វាយតាមអ្នកមានសីល ។
ថាម៉ែនៅរស់កូនម៉ែមិនដឹង
ប៉ុន្តែពេលនឹងកូនៗកុំខ្ជិល
ស្រណោះម្តាយស្លាប់កូនកុំមន្ទិល
ម៉ែពិតលែងវិលបើកូនឧស្សាហ៍ ។
ខ្មោចម៉ែទួញយំព្រោះអស់សង្ឃឹម
ខ្សោះលែងញញឹមកំព្រាអាត្មា
កូនៗលែងនឹកខ្មោចម្តាយឈឺផ្សា

លាហើយបុត្រាបុត្រីគ្រប់គ្នា ។
សូមកូនទាំងឡាយកើតចិត្តស្រណោះ
អាល័យអាលោះអ្នកម្តាយកំព្រា
ធ្វើបុណ្យថ្វាយទាននិងសង្ឃា
រឭកបូជាឧទ្ទិសជូនម៉ែ ។
ស្រណោះព្រលឹងព្រះព្រហ្មមុខបួន
កើតរោគស្គមខ្លួនមិនមានពេលល្ហែ
សូមអស់ប្រុសស្រីទាំងក្រុងនិងស្រែ
ក្រោកឡើងមាសស្នេហ៍គោរពព្រះរស់ ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៤២-បូជាកាយចិត្តដូនម៉ែ



រឿងរ៉ាវគ្រប់យ៉ាងដែលមានកន្លង
កូនបានឆ្លាំឆ្គងតាមចិត្តអប្រិយ៍
ធ្វើឱ្យរូបម្តាយចុកចាប់ឥតបី
ស្ទើរសូន្យជីវីចោលទ្វីបលោកា ។
ម៉ែស៊ូអាម៉ាស់រ៉ាប់រងគ្រប់យ៉ាង
ទោះកូនកោងកាងខិលខូចឫស្យា
ម៉ែនៅក្រាបលួនដោយចិត្តមេត្តា
ឱ្យកូនភ្លឺថ្លាកែខុសធ្វើត្រូវ ។
តែកូនមិនស្តាប់កូនរឹតបំពាន
ដើររុកទន្ទ្រានហោះធ្យានអាស្រូវ
រាល់ថ្ងៃមិនរៀនដើរលេងយប់ជ្រៅ
ឱ្យម៉ែចាំផ្លូវក្រែងកូនវិលប្រាណ ។

ធ្វើការរាល់ថ្ងៃព្រោះតែរូបកូន

សឹងស្លាប់បាត់សូន្យព្រោះកូនសាមាន្យ

មិនភ្លាក់អាត្មាលុះម៉ែស្លាប់ប្រាណ

ទើបកូនកល្យាណយល់ចិត្តអ្នកម្តាយ។

ម៉ែអើយម្តាយថ្លៃសូមលោកប្រណី

អាសូរអភ័យកូនសូមក្រាបកាយ

បូជាជូនព្រះកាយចិត្តជូនម្តាយ

សូមលើកហត្ថថ្វាយចំពោះអ្នកម៉ែ ។

សូមម៉ែកុំសោកសូមម្តាយកុំយំ

ឱ!អ្នកមានគុណលើសសមុទ្រទន្លេ

កាយចិត្តលោហិតនៃលោកទាំងទ្វេ

កូនសូមថ្មមថៃលុះគ្រាអវសាន្ត ។

កាយចិត្តនៃកូនទាំងប្រុសនិងស្រី

នឹងយកព្រះថ្លៃទុកក្នុងសន្តាន
កូនលែងយង់ឃ្នងលោកទាំងពីរប្រាណ
ថ្ងៃខែប៉ុន្មានបម្រើលុះក្ស័យ ។
លុះជីវិតកូនត្រូវមរណា
កូនមិនរអាសូមភ្ជាប់និស្ស័យ
ដើរតាមបណ្ឌិតមុនក្រោយសម័យ
សូមលោកកុំភ័យគ្រានេះទៅហោង ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៤៣-លោហិតម៉ែថ្ងូរ



លោហិតក្រហមសោកាទួញហៅ
ចំពោះកូនពៅមាសស្នេហ៍ជីវ៉ា
កូនមាសទឹកដប់ស្មើនិងសង្ហារ
សូមស្តាប់មាតាណាសំណព្វចិត្ត ។
កូនធំអស់ហើយប្រឹងប្រែងសិក្សា
ទោះនឿយអាត្មាព្យាយាមឱ្យស្ថិត
រៀងរាល់យប់ថ្ងៃត្រូវរៀនពិតៗ
មាសប្រាក់នៅជិតបើវិជ្ជាមាន ។
បើកូនស្តាប់ម្តាយកូនបានត្រឹមត្រូវ
គ្មានរឿងអាស្រូវឧបសគ្គរយលាន
បើកូនមិនត្រាប់តែកូនបំពាន
ភ្លើងទុក្ខស្រែកឃ្លានទាញយកកូនហើយ ។

បើបែបនោះមែនលោហិតម៉ែថ្លូរ
ទឹកភ្នែកជន់ចូរទុក្ខគ្មានកោះត្រើយ
ថ្លូរព្រោះខកចិត្តខុសបំណងហើយ
ឈឺផ្សាឥតស្បើយព្រោះកូនប្រុសស្រី ។
ដូច្នេះកូនៗឈរមើលមែនទេ
ពេលឃើញទុក្ខទ្វេនៃម្តាយពិសី
ចង់ឱ្យគាត់ស្លាប់ឬមានជីវី
សូមអ្នកលកលៃរើសឱ្យត្រឹមត្រូវ ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៤៤-ខែរជាកូននឹកដល់ម៉ែ



ឱ!ព្រះម៉ែអើយកូននឹកអ្នកម្ដាយ
ហ្មងសៅគ្មានណាយនៅក្នុងចិន្តា
អ្នកម៉ែមានគុណធំលើសលោកា
នឹកម៉ែណាស់ណានឹកកាលថ្នមកូន ។
រដូវរងាម៉ែយកទ្រូងម៉ែ
ធ្វើពូកខ្នើយទ្វេឱ្យដល់កូនស្ងួន
កុំឱ្យត្រជាក់ដល់កូននឹមន្ទួន
ម៉ែឈឺគ្រាំខ្លួនឱ្យតែកូនសុខ ។
ឥឡូវម៉ែឆ្ងាយឆ្ងាយកូនប្រុសស្រី
ឆ្ងាយដូចមេឃដីកូនសែនរងទុក្ខ
តើម៉ែយ៉ាងណាកូនៗស្មាញស្មុគ
បានសុខឬទុក្ខឈឺឬរងា ។

ម្តេចកម្មទុយ៌សឥតត្រាប្រណី
មកផ្តាច់និស្ស័យម៉ែកូនកំព្រា
ឱ្យព្រាត់បាត់កូនបែកព្រោះវេរា
ឱ្យម្តាយសោភារស់ឆ្ងាយបុត្រា ។
ម៉ែអើយៗម៉ែកូននឹកម្តាយណាស់
តែទាស់កម្មក្រាស់ឃាត់ឃាំងប្រហារ
ឱ្យកូននិងម៉ែព្រាត់ដូចមរណា
ថ្ងៃនេះឈឺផ្សាមាតានៅឆ្ងាយ ។
ខ្ញុំសូមផ្តែផ្តាំដល់កូនគ្រប់គ្នា
សូមកុំរុញរាគោរពកុំណាយ
បើអ្នកមានគុណនៅទាំងពីរកាយ
ចូរអ្នកខ្វល់ខ្វាយឱ្យបានទាន់ពេល ។
ប្រយ័ត្នហួសពេលនឹងត្រូវឈឺចាប់

ឈឺហួសគេកាប់លើទុក្ខកន្ទេល
សៅហ្មងជាខ្ទើយអ្នកកើយគ្រប់ពេល
ហើយបានដេកទ្រេលនៅក្នុងអវិចី ។
ណ្តើយ!មិត្តអើយធ្វើកុំប្រមាណ
មានពេលធ្វើបានអ្នកកុំចាំអី
ធ្វើឱ្យពេញចិត្តសុចរិតទាំងបី
ទើបលែងស្តាយអ្វីដែលកន្លងហួស ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៤៥-មិនសម...!



អ្នកស្អាតអ្នកល្អនិងបណ្ឌិត
ស្លាប់ចូលមកជិតច្រើនជំនុំ
ពោលពាក្យមិនសមកម្លោះក្រមុំ
កំពុងស្អាតស្អំស្រាប់តែមរណា ។
អ្នកនេះចេះណាស់ក្នុងលោកិយ៍
គ្មានប្រុសនិងស្រីប្រៀបអាត្មា
មិនសមស្លាប់សោះគួរអនិច្ចា
មិនសមសោះណាព្រោះនៅក្មេង ។
កាលពីម្សិលមិញគាត់ជួបខ្ញុំ
ឥឡូវទុក្ខធំសែនចំបែង
មិនសមស្លាប់សោះខ្ញុំនៅម្នាក់ឯង
តែនេះជាក់ស្តែងរឿងជីវិត ។

អ្នកខូចអ្នកល្អផងនានា
អស់ទាំងប្រជានឹងមូលមិត្ត
ត្រូវមច្ចុចាប់សម្លាប់ជីវិត
ទោះអង្វរចិត្តពិតនៅគ្មានន័យ ។
សូមគិតឱ្យត្រូវកុំបីស្រយុត
សូម្បីព្រះពុទ្ធផុតវិស័យ
ក៏នៅនិព្វានសាវកអាល័យ
នេះជានិស្ស័យរបស់ធម្មជាតិ ។
ស្ត្រីល្អនៅក្នុងព្រះសាសនា
ក៏ត្រូវមរណាចូលមកបៀត
លុកលុយប្រហារសែនជូរជាតិ
ដូច្នេះសូមញាតិកុំគិតមិនសម ។
អ្វីដែលបានកើតក្នុងលោកិយ៍

ក្រោមមេឃលើដីគ្មានអ្វីដែលហំ
ទោះមានលើសគេឋានៈធំ
ចុងក្រោមត្រូវសមព្រោះបែកធ្លាយ ។
ជួបហើយបាក់បែកគ្មានសិទ្ធិថា
ស្អប់ហើយស្នេហាកុំនិយាយ
ព្រោះរឿងនឹងសមធម៌បានទាយ
ហើយត្រូវរលាយក៏សមដូចគ្នា ។
ជួបមុនបែកក្រោយរស់ហើយស្លាប់
កើតមកមានស្រាប់ក្រោយខ្វះទ្រព្យា
គឺសុទ្ធតែសមហួសពណ៌នា
ចូលមិត្តគ្រប់គ្នាគិតថាសមទៅ ។
មុនយើងមិនខឹងក្រោប្រទូស
សត្វនិងមនុស្សចេះមួម៉ៅ

ចេះខាំចាក់ដោតពៀរហ្មងសៅ
រួចធ្លាក់រណ្តៅនរកអវិចី ។
នេះក៏សមដែរព្រោះមានកម្ម
ចងក្រៀកឱ្យស្រាំជាតិចាស់ថ្មី
ទោះអ្នកគិតថាមិនសមក្តី
តែព្រះជិនស្រីត្រាស់ថាអនត្តា ។
ជាកិច្ចបញ្ចប់សូមប្រុសស្រី
ក្មេងចាស់ម្តេចក្តីស្តាប់ធម៌សាស្តា
ហើយត្រូវយល់ព្រមដោយបញ្ញា
លុះត្រាចាស់ក្លាយល់ច្បាស់ច្បង ។
កំណើតយើងសមទោះមានក្រក្រី
ត្រូវខំឃ្មាតខ្មីកុំសៅហ្មង
ទានសីលភាវនាល្អឥតឆ្គង

សូមអស់ប្អូនបងធ្វើទៅព្រោះសម ។

រឿងដែលមិនសមសូមបងប្អូន

ចាំទុកក្នុងខ្លួនកុំច្រឡំ

បើធ្វើអាក្រក់នោះពិតមិនសម

កម្លោះក្រមុំត្រូវធ្វើល្អវិញ ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៤៦-ទោសរបស់ខន្ធ



ខន្ធៈប្រៃថាគំនរធំក្រៃ
ទុក្ខឥតឧបមេយ្យក្នុងជីវិត
ទាំងក្មេងទាំងចាស់ទុក្ខរួបរឹត
នេះជាទោសពិតរបស់ខន្ធា ។
រូបក្មេងតែងចាស់ជាធម្មតា
តាមពាក្យសាសនាហៅថាជរា
រួចហើយត្រូវឈឺចុកគ្រាំគ្រា
ឈ្មោះទុក្ខវេទនាប្រាកដណាស់ ។
អានិសង្សរបស់ខន្ធមិនច្រើនប៉ុន្មាន
ដែលយើងគ្រប់ប្រាណទាំងក្មេងចាស់
ទទួលក្បៀមក្បាន្តសុខតិចណាស់
តែទុក្ខក្រៃក្រាស់ព្រោះតែខន្ធា ។

កើតចាស់ឈឺស្លាប់គ្រប់ៗអាត្មា
ម៉ឺនសែនខ្លោចផ្សាតតពណ៌នា
នេះជាទោសខន្ធជាមេពួកមារ
ដូច្នេះគ្រប់គ្នាកុំវង្វែង ។
បើអ្នកវង្វែងនិងស្នេហា
ប្រកាន់ខន្ធថាខ្លួនជាក់ស្តែង
ទុក្ខគ្មានអ្នកកែវិលតតលែង
ខ្វល់តែខ្លួនឯងខន្ធតតប្រណី ។
ខ្ញុំសូមរម្លឹកដល់គ្រប់គ្នា
ថាកុំរុញរាយើងត្រូវឃ្លាតខ្ចី
លះខន្ធចេញទៅដើរចេញភពបី
ដើរតាមព្រះអរិយ៍គ្រប់ព្រះអង្គា ។
ជាទីបញ្ចប់ខ្ញុំសូមជូនបុណ្យ

ដែលគឺជាគុណល្អហួសពណ៌នា

សូមឱ្យលោកអ្នកផុតចាក់ខន្ធា

ត្រេកអរគ្រប់គ្នាសូមអនុមោទនា ។

**ដោយស៊ីន អក្ខរា ព.ស.២៥៥៦**



# ៤៦-មកតាមវាសនា ទៅតាមនិស្ស័យ



ពាក្យថា**វាសនា**សូមប្រុសនិងស្រី
ទាំងចាស់ក្មេងខ្ចីចាំគ្រប់អាត្មា
គឺការប្រព្រឹត្តហៅថាចរិយា
នេះជា**វាសនា**សម្រាប់ប្រុសស្រី ។
អ្នកដែលកើតមកទោះក្រឬមាន
ដែលបានរស់រានមានភាពប្រិមប្រិយ៍
មានទាំងឋានៈនៅលើលោកិយ៍
អ្នកចាស់និងថ្មីបានថ្កើននិងថ្កាន ។
រូបស្រស់ល្អឆើតសម្ផស្សសោភា
សមនឹងឫក្សពារហៅមហាចំណាន
ចេញពីវាសនាចំណារឱ្យបាន
ប្រសព្វក្បែមក្បាន្តដូចនៅសួគ៌ា ។

វាសនាចែងឱ្យកើតមកអស្ចារ្យ
ភពភ្លឺស្រស់ថ្លាហួសនឹងពណ៌នា
មានមុខសមមាត់នៅលើទ្រព្យា
នេះហើយគឺជាវាសនាតាក់តែង ។
បើបានល្អហើយអ្នកអ្ហើយកុំភ្លេច
វាសនារំលេចរម្លឹកក្តែងៗ
ត្រូវធ្វើល្អទុកកុំឱ្យចំបែង
បើភ្លេចជាក់ស្តែងទៅវិញឯងឯត ។
អ្នកកើតមកក្រមិនមានអ្វីៗ
នេះព្រោះប្រុសស្រីធ្លាប់ខុសពិតៗ
បុព្វជាតិមិនល្អមកពីគំនិត
បើចិត្តយើងគិតពិតតាមនិស្ស័យ ។
បើសិនបច្ចុប្បន្នអ្នកភ្ញាក់អាត្មា

ចម្រើនផលាកប់ទុកក្នុងវ័យ
មុនវាសនាអាក្រក់បច្ចុប្បន្នជោគជ័យ
ទៅតាមនិស្ស័យគឺបានសុខា ។
តែរឿងមួយទៀតសែនអាសូរក្រៃ
កើតក្នុងភពត្រៃចាកផ្ទៃមាតា
ចំត្រកូលក្រវណ្ណៈឫស្សា
ទៅមុខកាលណាងងិតមួហ្មង ។
កើតហើយងងិតទៅវិញងងិត
និស្ស័យវាសនាពិតពុកម៉ែប្អូនបង
គឺធ្វើខ្លួនឯងខ្លួនឯងអ្នកចង
ស្លាប់ទៅស្ពាយឆ្គងរហូតភពថ្មី ។
រីសត្វខ្លះទៀតកើតមកភ្លឺថ្លា
ស្លាប់ទៅកាលណាប្រទះរស្មី

បើនៅជាមនុស្សក៏ល្អឥតបើ
ស្លាប់តាមនិស្ស័យពូជជនកល្យាណ ។
វាសនាពុំមែននរណាប្រគល់
ហើយហុចឱ្យដល់ដៃជនគ្រប់ប្រាណ
តាមពិតមនុស្សទេវាសនាប៉ុន្មាន
អ្នករៀបចំថ្កានឱ្យដល់ខ្លួនឯង ។
គ្រប់គ្នាទាំងអស់អ្នកសាងវាសនា
មិនមែនទេវតាគ្មានព្រហ្មជាក់ស្តែង
គឺចិត្តអ្នកសាងទុកឥតបើលែង
កើតគ្រប់កន្លែងហួសនឹងការស្មាន ។
ជនខ្លះមួយទៀតវាសនាគម្រក់
ដេកដើរកុហកពេញទាំងសន្តាន
គ្រូប៉ោកគ្រូបិនបោកជនគ្រប់ប្រាណ

ហាស្តីប៉ុន្មានកុហកពិតៗ ។
កាលនៅក្រហស្តមិនអស់ចិន្តា
សាងផ្ទួសកាលណាត្រៀមនូវដួងចិត្ត
កុហកគេទៀតនេះវាសនាពិត
និស្ស័យឧក្រិដ្ឋរស់ក្រោមកិលេស ។
វាសនាខាងដើមនិស្ស័យខាងចុង
ដូច្នេះត្រូវប្រុងកុំឡើយប្រហែស
រៀបចំខ្លួនឯងឱ្យបានពិសេស
ទុកជាជំនិះជិះតាមនិស្ស័យ ។
សូមឱ្យអ្នកអានគ្រប់ៗវណ្ណា
សូមបានបញ្ញាប្រហារឱ្យក្ស័យ
នូវពូជកិលេសសូមបានជោគជ័យ
សូមលះភពត្រៃបាននិព្វាបហោង ។

ខ្ញុំសូមអភ័យប្រណីមេត្តា
បើសិនអក្ខរានាំឱ្យមួហ្មង
ខន្តីឱ្យទានមីងមាប្អូនបង
ព្រោះជាបំណងដ៏ល្អទេណា ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ៤៧-តម្រេករមែងនាំទុក្ខ



ជនអ្នកមានកូនតែងក្រៀមក្រំចិត្ត
ព្រោះស្អប់អាណិតនឹងក្តីស្នេហា
ត្រូវទុក្ខនឹងកូនលុះត្រាមរណា
ព្រោះដួងចិន្តាតម្រេកបុត្រក្រៃ ។
ជនអ្នកមានគោតែងតែទុក្ខក្រំ
ព្រោះគោតូចធំដែលកាន់ជាប់ដៃ
ទុក្ខព្រោះរក្សាទាំងយប់និងថ្ងៃ
គោនាំចង្រៃរហូតចិន្តា ។
អ្នកមានឧបធិតែងក្រំហ្ឫទ័យ
ជាអនុស្ស័យប្រហារសុខា
បង្កើតក្តីទុក្ខឱ្យពេញឱរា
ឧបធិនេះណានាំឱ្យចិត្តស៊ប ។

តែព្រះពុទ្ធអង្គសាស្តាភពបី

ស្តែងប្រាប់ប្រុសស្រីទ្រង់ពុំប្រឆើយ

ថាបើឧបធិកំចាត់ចោលហើយ

អ្នកនឹងបានស្បើយរហូតនិព្វាន ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ៤៨-ប្រទូស មិនស្មើតប



ជនណាចិញ្ចឹមនូវភរិយា
ព្រមទាំងបុត្តភ្ញាឱ្យបានសប្បាយ
ទាំងចេះឱ្យទានចិត្តគ្មានរសាយ
ប្រព្រឹត្តឥតណាយនឹងព្រះធម្មា ។
នឹងធ្វើការងារដោយក្តីខ្វល់ខ្វាយ
ឆន្ទៈចិត្តកាយពុំដែលមានរា
បុរសបែបនេះមិនគួរចងពៀរ
តែគួរភរិយាវន្ទាកោតក្រែង ។
តាមពុទ្ធតម្រាស់ពិតជាអស្ចារ្យ
គឺព្រះសាស្តាព្រះអង្គទ្រង់ចែង
បូជារាប់ពាន់មិនស្មើជាក់ស្តែង
លើសប្រុសចេះក្រែងខាងលើបានឡើយ ។
បើអ្នកប្រទូសពិតជាខុសណាស់

រស់ជួបកម្មក្រាស់ឥតមានល្អែល្អើយ
មិនស្មើនឹងតបបម្រើកៀកកើយ
ភរិយាបានស្បើយកូនបានសុខា ។
អស់កូនភរិយាទាំងគ្រប់ស្រទាប់
បើអ្នកមានភ័ព្វត្រូវប្រឹងប្រែងប្រាណ
ធ្វើល្អតបប្តីទើបអ្នកបានក្សាន្ត
រហូតអ្នកបានព្រះនិព្វានហោង ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៤៩-ដំណោះស្រាយផ្លូវចិត្ត



ចិត្តអត់ជឿកម្មចម្រើនសទ្ធា
បញ្ញាជាគ្នាជាគូសមពិត
ធ្វើចិត្តឱ្យក្លាយជឿល្អប្រណីត
ដោះស្រាយផ្លូវចិត្តពិតលែងយល់ខុស ។
ចិត្តណាស់តែខឹងឥតបីមានស្រាន្ត
ខឹងគេគ្រប់ប្រាណចិត្តនាំប្រទូស
អទោសៈមានកុំឱ្យរលុះ
ដោះស្រាយឱ្យអស់ចេញពីឱវាទ ។
ចិត្តស្រឡាញ់រូបព្រោះតែរាគៈ
ស្នេហ៍ឥតបើទាក់បន្តិចឡើយណា
ស្នេហ៍ណាស់ទុក្ខខ្លាំងដុតរោលចិន្តា
ធ្វើឱ្យឈឺផ្សាហួសនឹងបរិយាយ ។

វិរាគៈមានដោះស្រាយផ្លូវចិត្ត
ឱ្យស្បើយទុក្ខពិតថែមនាំឱ្យណាយ
ឆ្ងាយស្រឡាញ់ស្អប់ពីរូបនិងកាយ
ចិត្តបានស្រស់ស្រាយឥតមានអំពល់ ។
ចិត្តស្អប់ចិត្តទាស់ចិត្តដែលហួងហែង
ប្រណាំងប្រជែងចិត្តនាំកង្វល់
ត្រូវសង្រួមចិត្តតាមព្រះទសពល
អ្នកពិតអស់កលព្រោះបានអប់រំ ។
គ្រប់គ្រងទូន្មានឃាត់ឃាំងដួងចិត្ត
ឱ្យបានស្មើពិតនោះទុក្ខតូចធំ
នឹងត្រូវរសាយចិត្តបានស្អាតស្អំ
ទុក្ខលែងលាយឡំក្នុងចិត្តទៀតហើយ ។
សូមអស់បរិស័ទគ្រហស្ថបព្វជិត

ត្រូវអប់រំចិត្តមិនត្រូវកន្តើយ
សន្តិយើងបានគឺបានដល់ត្រើយ
ក្តីសុខល្អែល្អើយនឹងនិព្វាននាយ ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ៥០-ប្រពន្ធស្អាត ប្តីល្អ



ពាក្យប្រពន្ធស្អាតសូមស្តាប់ឱ្យបាន
អស់ប្រុសគ្រប់ប្រាណទាំងចាស់និងខ្ចី
ស្អាតកាយវាចាចិត្តផងគ្រប់បី
សុចរិតប្រិមប្រិយ៍នាងស្អាតគ្រប់យ៉ាង ។
សទ្ធាបញ្ញាមានក្នុងខ្លួនស្រី
ជឿមុនធ្វើអ្វីពុំមានកោងកាង
ជឿបាបជឿបុណ្យគុណល្អគ្រប់យ៉ាង
នួននាងស្មិតស្អាងតាមព្រះជិនស្រី ។
សតិហិរិនឹងឱតប្បា
ប្រពន្ធអស្ចារ្យហៅកល្យាណី
រលឹកខ្មាសបាបអំពើអប្រិយ៍
នាងតែងជោគជ័យនៅក្នុងជីវិត ។

ទានសីលភាវនានាងប្រកាន់ភ្ជាប់
ប្តីណាមានភ័ព្វព្រោះទេពធីតាស្តិត
គឺប្រពន្ធស្អាតនាងតែងនៅជិត
នាងនៅនៃបនិត្យបុណ្យឥតរសាយ ។
សម្មាទិដ្ឋិនាងតែយល់ត្រូវ
គំនិតជាផ្លូវនាំចិត្តនាំកាយ
ឱ្យដើរផ្លូវត្រូវប្រាប់ឪពុកម្តាយ
ឱ្យកូនទាំងឡាយសន្សំពូជបុណ្យ ។
បម្រើស្វាមីទុកដូចបិតា
ដាក់លើសិរសាឥតមានជិនឆ្អន់
ឬដូចបងប្រុសពោលពាក្យទន់ភ្លន់
រីនាងគោរពគុណស្វាមីដូចគ្នា ។
ឯស្វាមីល្អរបស់នួនស្រី

# តែងតែឃ្មាតខ្មីអើពើគ្រប់គ្រា
# ប្រកាន់គំនិតតម្កើងភរិយា
# ស្វាមីល្អជាប្រៀបបានទេវបុត្ត ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៥១-មិនគួរមានមានៈ ចំពោះបុគ្គល៥ពួក



១-គឺមាតាអ្នកឱ្យកំណើត

ប្រុសស្រីល្អឆើតជ្រែកទ្វីបលោកា

ត្រូវតែលំទោនចំពោះមាតា

ទើបបានវាសនាផុតកម្មអាស្រូវ ។

២-គឺបិតាបន្ទាប់ពីម៉ែ

លោកល្អផងដែរល្អពន់ពេកកូវ

ទោះមិនបង្កើតក៏លោកប្រាប់ផ្លូវ

ឱ្យប្រុសស្រីទៅដល់ភាពសុខសាន្ត ។

៣-គឺរៀមច្បងបន្ទាប់ឪម៉ែ

វន្ទាផងដែរវាចាចិត្តប្រាណ

ពោលពាក្យពីរោះចេះកោតសន្តាន

ឆ្ងាយភពសាមាន្យគឺកំណើតបួន ។

៤-គឺអាចារ្យជាគ្រូទីពីរ

លោកខំសម្តែបង្រៀនតាមក្បួន

ត្រូវអបចាយនៈលន់តួអង្គខ្លួន

ជោគជ័យសមសួនអនាគតថ្លៃថ្លា ។

៥-ព្រះអរហន្តសម្មាសម្ពុទ្ធ

ប្រសើរបំផុតនៅលើលោកា

សាវកប្រុសស្រីគ្រប់អង្គផងណា

អ្នកកាន់សាសនាវន្ទាកុំឆ្គង ។

បើមានមាននៈត្រូវកម្ចាត់ចេញ

កុំឱ្យទោម្នេញនឹងក្រោយមួហ្មង

ដេញមាននៈចេញណាញាតិប្អូនបង

# យើងសុខកន្លងរហូតនិព្វាន ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**



# ៥២-ចម្រើនសតិ អប់រំដួងចិត្ត



រស់នៅរាល់ថ្ងៃប្រុសស្រីគ្រប់ប្រាណ
ប្រឹងឱ្យចំណានកុំបីប្រហែស
ប្រយ័ត្នគ្រោះថ្នាក់បានដៃកិលេស
អ្នកលែងពីសេសក្លាយឥតខ្លឹមសារ ។
ក្មេងចាស់គ្រប់វ័យព្យាយាមហាមចិត្ត
កុំឱ្យប្រព្រឹត្តធម៌អកុសលា
ណែនាំគ្រប់ពេលឱ្យឆ្ងាយបញ្ហា
នោះទើបចិន្តាបានល្អសោភា ។
យើងអ្នកជ្រះថ្លាចំពោះត្រៃគុណ
ទាំងស្រឡាញ់បុណ្យទាំងខ្លាចវេរ
ត្រូវស្តាប់ឱវាទស្តេចព្រះភគវា
ចិត្តលែងក្រំគ្រោះព្រោះបានអប់រំ ។

ចិត្តឃើញចិត្តដឹងរឿងរ៉ាវគ្រប់យ៉ាង
ចិត្តជាចាងហ្វាងចិត្តជាប្រធំ
ប្រធានលើមនុស្សចាស់ក្មេងជំនុំ
ច្នេះត្រូវអប់រំឱ្យបានប្រពៃ ។
ត្រូវតែរឭករឿងរ៉ាវទាំងឡាយ
សតិក្នុងកាយនឹងក្នុងដួងចៃ
ចម្រើនសតិអប់រំចិត្តថ្លៃ
ទើបលែងចង្រៃនៅភពចាស់ថ្មី ។
សូមកុំច្រឡំគ្រប់រឿងបញ្ហា
វានឹងអសាររលុបបាត់អី
បើគ្មានសតិនៅតែជួបភ័យ
ទាំងប្រុសទាំងស្រីទុក្ខលុះអវសាន្ត ។
មិនមែនក្តីទុក្ខរសាត់តាមខ្យល់

រសាត់ឥតសល់ចេញពីសន្តាន
សតិរលាយទុក្ខកើតច្រើនថ្កាន
សូមអ្នកកុំស្មានថាទុក្ខអស់ឡើយ ។
បើមានក្តីទុក្ខសូមកុំយកស្រា
លេបធឹកពិសាបំបាត់ឱ្យស្បើយ
កុំឱ្យនៅណែនចុកសៀតឥតល្ហើយ
មិនត្រូវសោះឡើយរឹតតែខុសផ្លូន ។
កាលមិនទាន់ធឹកសតិនៅមាន
ខុសត្រូវរយលាននៅនឹងពេញខ្លួន
ធឹកស្រាពេលណាបែរចាប់ម៉ែកូន
ធ្វើបាបរុកកួនសង្គមខ្ពើមក្រៃ ។
ធឹកស្រាបាយឆ្ងាញ់តែកើតអកុសល
ឆ្ងាញ់តែកង្វល់នៅក្នុងភពត្រៃ

អណ្តាតឆ្ងាញ់ពិតតែឧបទ្រពក្រៃ
ស្រានាំចង្រៃហិនហោចកុសលា ។
ស្រាមិនចម្រើនសម្រាប់ប្រុសស្រី
តែអន្តរាយអ្វីព្រោះតែសុរា
វិនាសទ្រព្យធនចម្រើនអសារ
ដូច្នេះសុរាមិនចម្រើនឡើយ ។
បើមានសតិស្មើមហាមូលធន
ទាំងកូនប្រពន្ធបានក្សេមល្អែល្អើយ
ទាំងអ្នកនឹងគេសួគ៌ជិតបង្កើយ
គួរកុំកន្តើយចម្រើនឱ្យក្រាស់ ។
ឥរិយាបថបួនពុំបានប្រកាន់
តែវាគ្រប់គ្រាន់សម្រាប់ក្មេងចាស់
គ្រហស្ថបព្វជិតខំឱ្យបានណាស់

**សំឡៀងកំណាព្យ**

# សតិរឹតក្រាស់សុខកាន់តែក្រៃលែ ។

## ដោយសុិន អក្ខរា ព.ស.២៥៥៦



*រៀបរៀងដោយសាមណេរ* **១៧០** **ខន្តិសារោ សុិន អក្ខរា ព.ស.២៥៥៦**

# ៥៣-ចេះធម៌តែងនឹស តែចេះងាស់



និស្ស័យបុថុជ្ជនចង់ឡួយចង់ឆាយ
ចង់តែសប្បាយតែដឹងខុសត្រូវ
ស្គាល់តួនាទីប្រពន្ធកូនចៅ
ទោះបីខ្លួននៅគ្រហស្ថម្តេចក្តី ។
មិនយូរប៉ុន្មានឈានចូលវត្តវ៉ា
រៀនសូត្រធម៌អាថ៌នៃព្រះជិនស្រី
អប់រំកាយចិត្តឱ្យបានប្រពៃ
ចង់ឆ្លងភពបីព្រោះខ្ពើមខន្ធា ។
តែគួរសង្វេគមិនយូរប៉ុន្មាន
ធម៌ពេញសន្តានជាងជននានា
នឹកឃើញពោលបានយល់កម្មវេរា
យល់ច្បាស់ធម្មាមិនស្រពិលឡើយ ។

យូរទៅបន្តិចធម៌រឹតតែខ្លាំង
បែរជាប្រឆាំងឥតស្រាកពុំស្បើយ
ចេះធម៌មិនទើសតែទាស់ឥតល្ហើយ
ទុក្ខមកកៀកកើយព្រោះទាស់នេះឯង ។
គិតថាអស្ចារ្យពេលខ្លួនចេះធម៌
ទាំងខ្លួននោះញ៉ែរកិលេសជ្រោមជ្រែង
រៀនធម៌ប្រកាន់ធម៌ឧទានមិនលែង
ថាធម៌អញស្តែងរៀនមកកន្លង ។
គេធ្វើអីខុសព្រោះអត់ធម្មា
កើតពៀរវេរាកៀកកិតក្តីឆ្គង
តែខ្លួនចេះធម៌ច្រើនជាងអ្នកផង
តែបែរឆ្គាំឆ្គងលើសគេលើសឯង ។
អ្នករៀនព្រះធម៌អប់រំផ្លូវចិត្ត

តែមិនបានគិតអធម៌មកក្លែង
បន្លំឱ្យទាស់គ្រប់ទីកន្លែង
រៀនធម៌ឥតក្រែងទោសៈច្រើនក្រៃ ។
រៀនធម៌លះទាស់ទើបវាត្រូវច្បាប់
រឿងអ្វីក្រឡាប់អាក្រក់ចង្រៃ
មានហេតុមានផលឬមានបច្ច័យ
មិនប្រកាន់អ្វីទើបអ្នករៀនធម៌ ។
អស់ឧបាសកនិងឧបាសិកា
បើរៀនធម៌អាចសូមកុំញាប់ញ័រ
កុំទាស់កុំខឹងទើបកុសលធម៌
តាំងនៅបានល្អព្រោះធម៌បានជ័យ ។
បើរៀនធម៌ហើយនៅឡើយតែទាស់
សូមកុំក្រឡាស់ត្រូវតែលើកស្ទួយ

ឆន្ទៈព្យាយាមយកល្អជំនួយ

សង្ឃឹមថ្ងៃមួយអ្នកលែងទាស់ចិត្ត ។

តែទាស់ចិត្តខ្លះព្រោះភាពលម្អៀង

យល់មុខហើយល្មៀងអគតិសណ្ឋិត

ស្រឡាញ់នរណានោះមិនទាស់ចិត្ត

តែបើស្អប់ពិតនឹងទាស់ចិត្តហើយ ។

រៀនធម៌ចេះទាស់រៀនធ្វើអី

ខុសច្បាប់ជិនស្រីដែលទ្រង់ប្រាប់ហើយ

បញ្ឈប់ការទាស់ដោយមិនខឹងឡើយ

បែបនេះមែនហើយរៀនធម៌បានការ ។

សូមអ្នករៀនធម៌ទាំងប្រុសនិងស្រី

ត្រូវយល់សេចក្តីពិតតាមបញ្ញា

យល់និស្ស័យមនុស្សចូលចិត្តបែបណា

អ្នករៀនធម៌អាចំពិតលែងទាស់ហើយ។

ខ្ញុំសូមបញ្ចប់បញ្ឈប់អត្ថន័យ

ជនមាននិស្ស័យសូមកុំកន្តើយ

ព្យាយាមអានគិតចិត្តនឹងបានស្បើយ

សូមសុខដល់ត្រើយដល់អ្នកគ្រប់គ្នា ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៥៤-ស្រី...



ស្រីសចិត្តខ្មៅកុំទៅក្បែរ
កុំទៅសូមស្នេហ៍នាងធ្វើអី
នាងឱ្យយើងឈឺធ្លាក់អវិចី
ត្រឹមស្អាតសោភីគួរគណនា។
រីឯខាងក្នុងអាក្រក់ក្រៃ
ខ្ញុំប្រៀបឧបមេយ្យដូចផ្លែល្វា
ល្អតែខាងក្រៅដូចពងទា
ក្នុងស្អុយមហិមាហួសការស្មាន។
ស្រីខ្មៅចិត្តខ្មៅស្មានហួសគិត
ល្ងាចធឹកព្រឹកធឹកវាយឆ្នាំងចាន
បើនៅក្រមុំឫកហំហាន
បុរសណាបានពិតស៊ប់ធំ។

ស្រីខ្មៅចិត្តខ្មៅមិនស្តាប់ប្តី
មិនចេះរកស៊ីបានតែយំ
អាងតែទឹកភ្នែកមកបន្លំ
ស្រែកសោកទួញយំហួសនិស្ស័យ។
ស្រីខ្មៅចិត្តសល្អគួរគាប់
ប្រុសណាមានភ័ព្វបានសិរី
នាងចេះថ្នាក់ថ្នមដល់រូបប្តី
រក្សាប្រុសថ្លៃពុំដែលហ្មង។
ស្រីខ្មៅចិត្តសល្អពេកណាស់
នាងថែមមិនឆ្នាស់ដាក់អ្នកផង
ចរិយាមារយាទពុំដែលឆ្គង
ញញឹមផ្អៀងផ្អងគួរបេតី។
ស្រីសចិត្តសពិតអស្ចារ្យ

ល្អទាំងចរិយាទាំងពាក្យស្តី
គោរពម៉ែឪទាំងស្វាមី
ទាំងអ្នកដទៃពុំរុញរា។
ស្រីសចិត្តល្អពិតគួរខ្លាច
អំពើកោងកាចគ្មានដល់គ្នា
ធ្វើទានដាក់បាត្រផ្សាយផលា
នេះហើយកញ្ញាគួរសរសើរ។
សូមផ្តាំដល់ប្រុសគ្រប់ៗប្រាណ
ប្រាថ្នាសុខសាន្តឬសូមស្នេ
ចង់បានភរិយាមើលដំណើរ
កុំស្អាក់កុំស្ទើរត្រូវលកលៃ។
កុំអាលប្រញាប់ឆាប់ចង់បាន
កុំយកលុយឡានដាក់មុខស្រី

# កុំអាងខ្លួនមានកុំកែឆ្មៃ
# ល្មើសប្រពៃណីដូនតាយើង។

**ស.អ.ន.២០.១១.២០០៧**



# ៥៥-កុំ...



កុំអាងខ្លួនធំ ធ្វើបាបក្រមុំ
ឲ្យនាងរឹងរៃ កុំអាងស័ក្តិខ្ពស់
បំផ្លាញទឹកដី កុំថាមិនអី
កុំថាមិនបាន។
កុំស្រែកឮខ្លាំង ប្រយ័ត្នចូលឆ្នាំង
ប្រយ័ត្នក្សួយប្រាណ កុំដូចកង្កែប
ស្រែកឮហួសស្មាន ហោងស៊ីយគេបាន
ខ្វារចេញពីរន្ធ។
កុំថាស្រមោច តិចលោហិនហោច
ទទួលអាសន្ន កុំថាគេតូច
កុំអាលជិះជាន់ ប្រយ័ត្នស្លោស្លន់
ទទួលមរណា។

កុំទាន់អាលដើរ រួចមើលដំណើរ
ផ្លូវឆ្ងាយបែបណា កុំសង្ឃឹមពេក
ប្រយ័ត្នសោកា កុំថាសុខា
កុំទាន់អាលត្អូញ។
កុំទាន់ហ៊ីហា កុំធ្វើអាចារ្យ
កុំមើលងាយប្អូន កុំអាលថាចេះ
កុំទាន់ថាសូន្យ កុំទាន់ហៅអូន
កុំទាន់យកចិត្ត។
ពាក្យកុំទាំងនេះ កុំភ្លេចត្រិះរិះ
កុំចោលគំនិត កុំអាលថាធុញ
កុំភ្លេចទៅជិត កុំភ្លេចរកមិត្ត
កុំគប់ពាលឡើយ។ **ស.អ.រ ២០.១១.២០០៧**

# ៥ខ-ទ្រព្យ...

(បទពាក្យ ៨)ស.អ.រ ២១.១១.២០០៧



ទ្រព្យធ្វើឱ្យមនុស្សឈ្លោះប្រកែកគ្នា
ទ្រព្យចងវេរានៅក្នុងលោកិយ៍
ទ្រព្យឱ្យអ្នកខ្លះភ្លេចអស់ទឹកដី
ទ្រព្យឱ្យប្រុសស្រីប្រព្រឹត្តអនាចារ។
ទ្រព្យធ្វើឱ្យយើងភ្លេចអស់ប្រពៃណី
ទ្រព្យនេះចង្រៃសាហាវដូចខ្លា
ទ្រព្យសែនទុយ៌សទ្រព្យនោះឬស្សា
ទ្រព្យឱ្យស្នេហាបាត់បង់មង្គល។
ទ្រព្យឱ្យមនុស្សស្លាប់ពីក្មេងក៏មាន
ទ្រព្យអាចបំពានហើយឱ្យកង្វល់
ទ្រព្យឱ្យជួបទុក្ខទ្រព្យឱ្យខ្វាយខ្វល់

ទ្រព្យនាំអំពល់ទ្រព្យឱ្យភ្លេចខ្លួន។
ទ្រព្យនេះធ្វើឱ្យលែងស្គាល់បងប្អូន
ទ្រព្យនាំសាបសូន្យទ្រព្យគ្មានសិរី
លាភយសសរសើរទ្រព្យនេះគ្មានន័យ
ដុល្លារអ្វីៗទ្រព្យគ្មានខ្លឹមសារ។
ទ្រព្យអើយបងទ្រព្យម្តេចបងឃោរឃៅ
ឱ្យមនុស្សរស់នៅទ្រព្យឥតមេត្តា
ធ្លាក់ទៅនរកព្រោះទ្រព្យឯងណា
ទ្រព្យឱ្យមនុស្សាចុកចាប់រឹងរែ។
សូមអ្នកអានយល់ហើយសូមករុណា
សូមយកបញ្ញាមកកែឆ្នៃ
ទ្រព្យធ្វើឱ្យយើងល្អឬចង្រៃ
បងប្អូនលកលៃកុំខឹងខ្ញុំឡើយ។

# សំឡៀងកំណាព្យ

# ស.អ.រ ២០.១១.២០០៧



*រៀបរៀងដោយសាមណេរ ១៨៤ ខន្តិសារោ សុន អក្ខរា ព.ស.២៥៥៦*

# ៥៧-ទឹកដោះម៉ែ

(បទពាក្យ៨)



រូបខ្ញុំកើតមកពុំបានជួបម៉ែ
សល់ទុកនៅតែឈ្មោះម៉ែប៉ុណ្ណោះ
រូបកូនទួញសោកយំសែនស្រណោះ
បានត្រឹមបៅដោះធំឡើងបាត់ម្តាយ។
ទឹកដោះម៉ែខ្ញុំផ្គុំបានជាគុណ
ធ្ងន់អើយសែនធ្ងន់មកលើចិត្តកាយ
ទឹកឈាមទឹកដោះអ្នកម្តាយឆោមឆាយ
ស្តាយអើយសែនស្តាយមិនបានរក្សា។
ទឹកដោះមួយតក់មានគុណច្រើនហួស
មកលើកូនប្រុសប្រោសនូវសង្ហារ
ឱ្យកូនរស់ធំបែរឃ្លាតកាយា

ទ្រូងកូនសោកាអល់អែកអាល័យ។

ពេលនេះព្រាត់ម៉ែកូនព្រួយសៅហ្មង

ស្រែកផងយំផងបេះដូងរីងរៃ

កូនស្រែករកម៉ែស្ទើរតែក្សិនក្សយ

កូនព្រាត់ម៉ែថ្លៃហើយណាម្តាយស្ងួន។

យកដៃគង់ថ្ងាសស្រណោះគ្រាមុន

និយាយស្រទន់លួងលោមកូនស្ងួន

កូនទ្រហោយំអ្នកម្តាយនឹមនួន

ម៉ែថ្នមអង្រួនបំពេរក្បា។

អនិច្ចាម៉ែអើយកូនសែនខ្លោចចិត្ត

ទំនួញជីវិតកូនអនាថា

ខ្វះភាពកក់ក្តៅគ្មានម្តាយស្នេហា

ទ្រូងកូនពើតផ្សាស្ទើរសូន្យវិញ្ញាណ។

ទឹកដោះម៉ែថ្លៃថ្លៃហួសការស្មាន
ពុំអាចរាប់បានគ្មានអ្វីស្មើគ្មាន
ទោះលុយរាប់ម៉ឺនច្រើនរយសែនលាន
មិនអាចប្រៀបបានទឹកដោះម៉ែឡើយ។
ព្រោះហេតុដូច្នេះសូមក្រើនរម្លឹក
ដាស់តឿនល្ងាចព្រឹកសូមកុំកន្តើយ
ប្រណិប័តន៍ពុកម៉ែកុំប្រមាទឡើយ
ចុងក្រោយបានសោយបុណ្យដែលអ្នកសាង។
ទោះក្របមានកុំភ្លេចម៉ែឪ
សម្រុកធ្វើទៅកុំបីបំពាន
កុំបំភ្លេចគុណហើយប្រឹងធ្វើទាន
ពុកម៉ែជាស្ពានចម្លងប្រុសស្រី។
ដូចជាព្រះពុទ្ធព្រះអង្គត្រាស់ដឹង

ព្រោះពុកម៉ែហ្នឹងបង្កើតបារមី
ត្រាស់ជាព្រះពុទ្ធដោយសារគុណថ្លៃ
ជួយញុំាងបារមីឱ្យត្រាស់ដឹងធម៌។
ព្រះពុទ្ធបានត្រាស់ទ្រង់សម្តែងថា
មាតាបិតាជាព្រះដ៏ល្អ
មានគុណសម្បើមបរិសុទ្ធិបវរ
គួរយើងត្រេកអរគោរពបូជា។
សូមផ្តាំប្រុសស្រីអស់ទាំងប្អូនបង
កុំមើលរំលងគ្រូបុព្វាចារ្យ
ក្រាបថ្វាយបង្គំមាតាបិតា
ស្លាប់ជាតិណាៗយើងបានសុខសាន្ត។

**ស.អ.ន. ២១.១១.២០០៧**

# ៥៨-បណ្តាំយាយ

(បទពាក្យ៧)



បណ្តាំផ្តាំចៅស្ងួនស្រស់ស្រី
ចៅកុំស្លៀកខ្លីពូជយើងមាន
ជាមួងចងក្បិនកុំបំពាន
ឱ!ចៅកល្យាណខ្លួនជាស្រី។
កុំទាន់សម័យចៅមាសស្ងួន
យាយផ្តាំផ្ងួនៗណាចៅពិសី
ចៅកុំជឿគេនាំរីងរៃ
សូមស្រស់ឆវីស្តាប់យាយណា។
ចៅអើយចៅស្ងួនស្រស់ស្រអែម
កុំជឿពាក្យផ្អែមណាជីវ៉ា
គេលួងលោមចៅបោកកាយា

ស្មោះណាស់ស្នេហាតែនឹងមុខ។

ក្រោយខ្នងបែកបែរកស្រីថ្មី

ឱ្យចៅរឹងរៃបានក្តីទុក្ខ

បើចៅស្តាប់យាយចៅបានសុខ

ហើយស្រីផុតទុក្ខរួចកង្វល់។

ឱ!ចៅស្រីអ្ហើយកុំបំពាន

ប្រពៃណីមានណានិមល

ចួនគេយកលុយឱ្យចៅខ្វល់

បំភាន់បំពុលឱ្យភ្លេចខ្លួន។

តើចៅឃើញទេខ្លះត្រូវស្លាប់

ព្រោះតែជឿឆាប់ពេកនឹមនួន

ខ្លះលោតទឹកស្លាប់ខ្លះបំពួន

បណ្តោយឱ្យខ្លួនរស់ខ្លោចផ្សា។

យាយផ្តាំមិនខុសទេពាលពៅ

យាយផ្តាំឱ្យត្រូវតាមវាសនា

ប្រព្រឹត្តចុះចៅតាមសម្មា.

ព្រះពុទ្ធថាស្វែងរកត្រូវ។

ចៅប្រុសដូចគ្នាដូចចៅស្រី

ចៅត្រូវស្តាប់យាយណាប្រុសពៅ

បើស្រឡាញ់ស្រីទោះសខ្មៅ

សំដៅឱ្យជ្រៅត្រង់សន្តាន។

ស្រស់ស្រីបស្រាយស្រៀវលើកាយា

ស្និទ្ធស្នើស្នេហាពេញអង្គប្រាណ

ចែចង់ចិត្តចៅស្រស់កល្យាណ

ខកខានខិលខូចព្រោះមិនស្តាប់។

ណែនាងនួននីបូជាស្រស់

ព្រឹត្តិការប្រុសៗច្រើនតែស្លាប់
គឺគូគាប់គួរចៅមិនស្តាប់
ពូកែជឿឆាប់ឥឡូវយ៉ាងណា។
ឱ!ចៅប្រុសអើយចាំសម្តី
ពាក្យផ្អែមកប់ន័យខ្លាំងអស្ចារ្យ
ចុងក្រោយសម្លាប់ក្បាយសង្ហារ
នេះហើយចៅណាមិនជឿយាយ។
បណ្តាំយាយពិតឥតភរ៉ា
បានជាលោកតាស្នេហាយាយ
ព្រោះជឿពាក្យចាស់តាមទំនាយ
តាលួចស្នេហ៍យាយកាលក្រមុំ។
ក្រមុំស្នេហ៍ប្រុសបានវិជ្ជា
ស្រីគ្មានមាយាចរិយាសមរម្យ

យាយលួចស្នេហ៍តាវិជ្ជារួមផ្សំ
កុំបីបង្ខំប្រយ័ត្នសូន្យ។
នេះបណ្តាំយាយផ្តាំគ្រប់ចៅ
ឱ្យចៅធ្វើត្រូវតាមច្បាប់ក្បួន
ពាក្យពេចន៍បូរាណពិតមាំមួន
ចៅត្រូវថែថួនប្រយ័ត្នខុស។

**ស.អ.ន. ២៣.១១.២០០៧**



# ៥៩-បកិណ្ណកៈអ្នកបួស

(បទពាក្យ ៧)



មុននឹងថ្លាថ្លែងខ្ញុំសូមទោស
សូមក្តីសន្តោសពីអ្នកបួស
ក្រុមពួកបរិស័ទសូមអត់ទោស
រាល់ពាក្យដែលខុសមិនត្រូវចិត្ត។
ចាប់ផ្តើមតែងចារថ្ងៃដប់ប្រាំពីរ
ប្រមូលមូលមីនូវរឿងពិត
ពីពាន់ដប់មួយមិនប្រឌិត
ថ្ងៃអង្គារជិតក្បែរម៉ោងបី។
ទីមួយអ្នកបួសបានពីក្មេង
បួសគិតតែលេងប្រចាំថ្ងៃ
បួសក្មេងខ្លះទៀតខំឥតបី

រៀនប្រចាំថ្ងៃឥតមានល្ហែ។
បួសក្មេងខ្លះទៀតសម្លឹងធំ
ចង់ឱ្យខ្លួនហាំស្មើនឹងគេ
បួសក្មេងចិត្តក្មេងចិត្តរារេ
នេះមិនល្អទេណាញាតិ៉ា។
បួសក្មេងខ្លះទៀតធំមិនទាន់
រហន់រួសរាន់មានស្នេហា
ពាក្យពេចន៍អូនបងឥតរអា
ចេះប្រើភាសាហួសនឹងវ័យ។
បួសក្មេងខ្លះទៀតចិត្តយោរយៅ
បួសដើរខុសផ្លូវព្រះអរិយ
ផ្តាច់បង់សង្ហារមិនប្រណី
បោះជើងលើកដៃទៅប្រហារ។

បួសក្មេងខ្លះទៀតចេះលួចលាក់
គ្មានគ្រូពញ្ញាក់ដាស់អាត្មា
បើគេទូន្មានមិនយកសោតា
គិតធ្វើបែបណាអាចារ្យភ័យ។
ឯអ្នកកម្លោះបួសវិញណា
ឫកពារហឺហាសែនសមក្រៃ
ល្អគ្មានគូដូចលើលោកិយ៍
ធ្វើឱ្យស្រីៗលង់ស្នេហា។
កម្លោះខ្លះទៀតបានបួសហើយ
បណ្តែតបណ្តោយតាមតណ្ហា
បួសមួយអាទិត្យទារលាសឹក្ខា
សូមសឹកហើយណាកុំឃាត់អី។
ខ្លះទៀតបួសពិតមិនក្លែងក្លាយ

បួសព្រោះតែណាយកាមលោកិយ៍
ខ្ពើមស្អប់កិលេសធម៌អប្រិយ៍
បដិបត្តិរាល់ថ្ងៃប្រាថ្នានិព្វាន។
ទោះបីយ៉ាកយ៉ាប់ក៏ប្រឹងប្រែង
ឆន្ទៈមិនលែងជាបធាន
មិនរាឥតថយខ្ជិលមិនមាន
មិនហ៊ានបំពានពុទ្ធវិន័យ។
អ្នកបួសខ្លះទៀតតាំងឫកឈ្លើយ
មិនកៀកខ្ពើមកើយតាមដួងចៃ
ស្អប់វិន័យព្រះថាចង្រៃ
មិនតាមជិនស្រីថាតឹងតែង។
ទាំងវត្តបដិបត្តិដើម្បីខ្លួន
មិនមាំមិនមួនឥតខ្លាចក្រែង

ប្រាថ្នាលាភយសពុំរអែង
សត្វមាន់មានស្នែងជល់ក្របី។
អ្នកបួសខ្លះទៀតបានរៀនចេះ
ស្រូបយកចំណេះបានប្រពៃ
មិនជួយសង្គមតែជួយស្រី
ខំរៀនរាល់ថ្ងៃព្រោះតែនាង។
រៀនចប់បណ្ឌិតតែចិត្តពាល
ទុំមុនស្រគាលរស់បង់វាង
ដែកកើតជាឡានមុនហោជាង
នេះព្រោះនួននាងឬព្រោះអ្នក។
អ្នកបួសខ្លះទៀតល្អហួសគិត
សំពត់រុំជិតនាមសាវក
បដិបត្តិវិន័យនោះគ្មានទាក់

តាមព្រះឥតជាក់ក្នុងសាសនា។

ដល់ពេលសឹកវិញសែនតក់ស្លុត
កើតក្តីស្រយុតក្នុងឱរា
ភ្លេចខ្លួនធ្លាប់បួសលង់អាត្មា
ឱ្យស្រីឱ្យស្រាលេងជីវិត។

អ្នកបួសខ្លះទៀតគិតឈ្លោះគ្នា
ប្រមូលផ្តុំពៀរឱ្យសណ្ឋិត
ឈ្លោះនឹងអាចារ្យនិងញាតិមិត្ត
អញមិនសុខចិត្តព្រោះវាទេ។

កាប់ចាក់គ្នាឯងអន់ជាងសត្វ
កុសលរត់បាត់បាបមកក្បែរ
នរករង់ចាំជាថ្ងៃខែ
មិនគិតរារេខំរឿងឈ្លោះ។

អ្នកបួសខ្លះទៀតរឿងកើតឡើង
គឺរឿងស្បែកជើងតែប៉ុណ្ណោះ
សរសេរពាក្យហាមឥតស្រណោះ
គេមិនតាមសោះអាងសម្លឹង។
ខ្លះទៀតមិនគួរនឹងពោលទេ
គឺរឿងសត្វឆ្កែនោះប៉ុណ្ណឹង
ធាក់ទាត់វាយគ្នាខ្លាំងម្លឹងៗ
ចិត្តគ្មានរំពឹងឥតមេត្តា។
អ្នកបួសខ្លះទៀតខឹងរហន់
គឺរឿងបង្គន់ហួសចិត្តវ៉ា
ជេរដល់សាមណេរភិក្ខុណា
មិនចេះឧស្សាហ៍គ្រាន់តែគូថ។
រករឿងរាល់ថ្ងៃឥតខ្មាសឡើយ

មិនមានកន្តើយឥតរបូត
ចង្អុលគេឯងនោះយ៉ាងស្រួត
រឿងនេះគួរស្លូតមានមេត្តា។
អ្នកបួសខ្លះទៀតឈ្លោះឥតគួរ
គឺរឿងសាប៊ូដូសកាយា
គេយកទៅប្រើឥតវាចា
ស្តីបន្ទោសថាពុំប្រណី។
គម្រាមគេថាបើថ្ងៃក្រោយ
បើខ្ញុំមិនឱ្យកុំយកដៃ
ប៉ះសាប៊ូខ្ញុំប្រយ័ត្នវាយ
ឱ្យស្គាល់ស្នាដៃអាត្មាម្តង។
អ្នកបួសខ្លះទៀតសូត្រធម៌អាថ៌
ច្រឡំផ្តាប់ផ្ងារកើតមួហ្មង

ខឹងអាចារ្យប្រាប់ព្រោះខ្លួនឆ្គង
ខុសបានតែម្តងម្តេចថាស្តី។
អាចារ្យខំប្រាប់យល់ថាខុស
បែរមិនសន្តោសឥតប្រណី
ចរចារតាំងច្បាំងថាមិនអី
ចាំបាច់លកលៃអាត្មាក៏ដឹង។
ខ្ញុំសូមបញ្ចប់សង្ខេបខ្លី
ទាំងប្រុសអស់ស្រីកុំទាន់ខឹង
មុននឹងស្អប់ខ្ញុំគួរយល់ដឹង
ថ្នមថ្នាក់ចិត្តហ្នឹងឱ្យប្រពៃ។

**ស.អ.រ.២១.០៨.២០១១**

# ៦០-ចំណុចថ្មីយ៉ាងថ្ងៃមាឃបូជា



សូមក្រាបបង្គំព្រះសាស្តា
ឱននូវសិរសាថ្វាយវន្ទា
គោរពជ្រះថ្លាឥតរួញរា
គ្រប់ពេលវេលាក្នុងឱវា ។
យើងស្តាយទ្រង់ណាស់ទ្រង់និព្វាន
បរិស័ទរយលានស្តាយសន្ធា
នឹកទ្រង់ធ្លាប់ពោលប្រោសទេសនា
ឥឡូវនេះណាយើងកំព្រា ។
ឱ!ព្រះអង្គអើយថ្ងៃនេះណា
បរិស័ទត្រៀបត្រាមកបូជា
មានផ្កាក្រអូបមកលីលា
នាថ្ងៃមាឃដ៏អស្ចារ្យ ។

នៅសកលលោកដែលបានយល់

ហើយធ្លាប់បានស្គាល់កាន់សាសនា

ជនជាតិគ្រប់សាស្ត្រស្រក់ទឹកនេត្រា

ស្តាយអ្វីម្ល៉េះណាមិនបានគល់ ។

ឱះ!ឱ!ព្រះអង្គនៅថ្ងៃនេះ

យើងបានចាំចេះថ្ងៃទសពល

កើតភាពចម្លែកគ្មានអ្នកដល់

ពួកយើងមិនឆ្ងល់តែជ្រះថ្លា ។

មានប្រាំចំណុចយើងពណ៌នា

ជាទីរម្មនាក្នុងចិន្តា

គ្រហស្ថបព្វជិតគ្រប់អាត្មា

នឹកថ្ងៃនេះណាគ្រប់វេលា ។

ទី១គឺខែរះពេញវង់

យាត្រាត្រចង់ចរលីលា
នៅលើអាកាសរស្មីថ្លា
ឱ្យពួកមហាជនបេតី ។
ថ្ងៃ១៥កើតខែមាឃា
រស្មីចន្ទ្រាល្អប្រិមប្រិយ៍
បំភ្លឺចាំងចែងពេលរាត្រី
ទាំងប្រុសទាំងស្រីពេញចិត្តរ៉ា។
ទី២ភិក្ខុសង្ឃទាំងឡាយ
និមន្តមកហើយឥតនរណា
និមន្តមកសោះតែយាត្រា
មកគាល់សាស្តាយ៉ាងរហង់ ។
សុទ្ធជាព្រះអរហន្តជាឯហិ
គ្រប់គ្រងសតិបានយ៉ាងត្រង់

គ្មានបុថុជ្ជនទេមួយអង្គ

មានភ័ក្រផូរផង់គួរជ្រះថ្លា ។

ទី៣មុនីអង្គជិនស្រី

ទ្រង់បានពោលស្តីនិងទេសនា

ឱវាទបាតិមោក្ខផ្ចាល់វាចា

ដូចយើងអត្ថាខាងក្រោមនេះ ។

**ខន្តីតប**ៈធម៌ថ្លៃថ្លា

អ្នកគ្រប់អាត្មាត្រូវឃ្លាតខ្ចី

ជាធម៌ឧត្តមក្នុងលោកិយ៍

នេះជាទ្រឹស្តីព្រះមុនី ។

ហើយដាក់សង្ខារនិងមុខមារ

ទ្រង់លាភិក្ខុភិក្ខុនី

ពេលនោះញាប់ញ័រអស់ផែនដី

ស្តាយព្រះជិនស្រីគ្រប់ៗគ្នា ។

**ទី៤**គឺទ្រង់បានសម្តែង

ជាផលជាក់ស្តែងក្នុងគិរី

ឱ្យព្រះសាវកខាងស្តាំនៃ

បានទីជោគជ័យគឺមគ្គផល ។

គឺឈ្មោះទីឃៈនខសូត្រ

សម្តែងរហូតដោះចម្ងល់

ដល់បរិព្វាជកឱ្យអស់ឆ្ងល់

សោតាបត្តិផលសម្រេចភ្លាម។

គ្រានោះព្រះសារីបុត្តថ្លៃ

ទទួលជោគជ័យបានជានាម

អរហន្តល្អឯកសាវកស្តាំ

បរិស័ទចេះចាំដល់សព្វថ្ងៃ ។

**ទី៥**ខែមាឃព្រះសាស្តា
ទ្រង់បានស្ថាបនាសាវកទាំងពីរ
មានឆ្វេងមានស្តាំដ៏សោភី
នេះគឺជាថ្ងៃមាឃបូជា ។
តែអស់យើងខ្ញុំបែកព្រះស្រី
ព្រាត់អង្គជិនស្រីស្តេចភគវា
ឃើញតែព្រះរូបមិនចេះចរចារ
យើងខ្ញុំនេះណាខ្លោចផ្សាក្រៃ ។
ឃើញតែព្រះធាតុពណ៌ឆ្អិនឆ្អៅ
ទុកសម្រាប់នៅជនប្រុសស្រី
មានពោធិព្រឹក្សល្អគ្មានបី
បូជារាល់ថ្ងៃមិនអស់ឱរា ។
បរិស័ទខ្លះទៀតសង្វេគក្រៃ

ទឹកភ្នែករំដែលហូរយាត្រា

ទ្រហោដូចកាលព្រះសាស្តា

ជាក់នូវសង្ខារចូលនិព្វាន ។

យើងខ្ញុំសូមថ្វាយនូវផ្កាភ្ញី

ថ្វាយព្រះមុនីនៃទ្រង់ញាណ

សូមឱ្យយើងខ្ញុំបាននិព្វាន

ជាទីអវសាន្តកុំខានឡើយហោង។

**ដោយសុិន អក្ខរា ព.ស.២៥៥៥**

# ៦១-ភ្នែកមើលតួក្រៅ ចិត្តមើលជល់ក្នុង



បើកភ្នែកកាលណាមើលឃើញយល់
ត្រូវទាស់អំពល់សែនស្នេហា
រូបល្អស-ខ្មៅចាស់ក្មេងយាយតា
ចក្ខុធម្មតាមើលឃើញខាងក្រៅ ។
រូបសល្អរាងស្រស់ឆើតឆាយ
ភ្នែកគន់មិនណាយគ្មានក្តីមួម៉ៅ
មើលលើមើលក្រោមមើលផ្តាំញាតិជៅ
ផ្តាំដល់កូនចៅព្រោះតណ្ហា ។
ប្តីមើលប្រពន្ធភរិយាមើលប្តី
មើលដោយភក្តីនិងស្នេហា

ចក្ខុឆ្លងឆ្លើយព្រោះកាមវិតក្កា
បានដៃមោហាវិលវល់ឥតស្រាន្ត ។
មំសៈចក្ខុគឺឃើញធម្មតា
ឃើញអស់សត្តាល្អហួសប្រមាណ
ល្អប្រុសល្អស្រីញាតិផៅប៉ុន្មាន
ឃើញគ្រប់សន្តានសុទ្ធតែប្រពៃ ។
តែចិត្តអាក្រក់ភ្នែកអត់ដឹង
ងងិតសូន្យឈឹងទាំងប្រុសស្រី
ជួនរូបឆាយឡួយចិត្តអប្រិយ៍
ភ្នែកអត់ដឹងអ្វីបានត្រឹមឃើញយល់ ។
តែបើចិត្តវិញមើលធ្លុះមនុស្ស
ប្រទូសមិនប្រទូសគឺចិត្តស្គាល់
លោភលួចលាក់លៀមច្រើនល្បិចកល

ចិត្តនៅតែយល់បែងចែកស-ខ្មៅ ។
ចិត្តដែលភ្លឺស្វាងដោយបញ្ញា
តែងចរយាត្រារកផ្លូវត្រូវ
ប្រាប់រឿងទាស់គាប់ល្អហួសកូវ
ចិត្តនេះអ្នកដៅដឹងហត្ថគ្រប់គ្នា ។
ចិត្តតែងមើលមនុស្សធ្លុះក្នុងក្រៅ
ឃើញអស់ញាតិដៅដែលគួរចាកពៀរ
មើលប្តីប្រពន្ធដែលចេះសាមគ្គា
ដឹងអស់ប្រជាពាលនិងកល្យាណ ។
ដូច្នេះបរិស័ទដែលមានដួងចិត្ត
ត្រូវខំប្រណិតកុំបែរប្រាណ
លត់ដុំដួងចៃកុំឱ្យសាមាន្យ
ចិត្តមានគ្រប់ប្រាណសាងចិត្តឱ្យថ្លា ។

ដុតបំភ្លឺចិត្តដោយភ្លើងអប់រំ
ចាប់ចិត្តបន្ទុំសតិបញ្ញា
យកត្រូវលាងខុសចោលចិត្តឫស្យា
ទើបចិត្តភ្លឺថ្លាសម្រេចបានញាណ ។
សង្ខេបប៉ុណ្ណោះទុកជូនញាតិគិត
ហើយសូមឱ្យស្ថិតដិតជាប់សន្តាន
ភ្នែកភ្លឺចិត្តភ្លឺវារិតចំណាន
**អក្ខរា**ចង់បានចិត្តភ្លឺនោះឯង ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ៦២-ហិរិ + ឱត្តប្ប:



ហិរិក្រមុំមេម៉ាយឱត្តប្បា
សក្កសមអស្ចារ្យជាបុត្រព្រះស្រី
ទានដូចក្រមុំសែនល្អសម្ដី
សីលមេម៉ាយស្រីពិសីសោភា ។
សទ្ធាក្រមុំសតិមេម៉ាយ
ស្រីដែលឡូយឆាយមិនស្មើបាទា
មេម៉ាយក្រមុំដែលមានសទ្ធា
ព្រោះពូជល្អជាភ្ជាប់វង្សទេវតា ។
ក្រមុំអលោភោស្អប់ណាស់លោភា
មិនដែលក្រំគ្រាមានអទោសា
មេម៉ាយអមោហ៍ពិតមានខ្លឹមសារ
បុរសជនណាបានពិតហេងក្រៃ ។

មេត្តាក្រមុំមេម៉ាយករុណា
មេម៉ាយមុទិតាផ្តិតជាប់ដួងចៃ
ក្រមុំឧបេក្ខាជាប់មិនអាល័យ
សាវិកាព្រះស្រីជារោគដួងចិត្ត ។
ហិរិកម្លោះបុរសឧត្តម
ឱត្តប្ប:រួមផ្សំសតិមូលមិត្ត
កម្លោះក្រមុំដៃគូនៃបនិត្យ
ប្រសូត្របុត្តពិតបានដល់ផលា ។
បញ្ញាក្រមុំវិមត្តិមេម៉ាយ
ទោះឥត្ថីកាយឬបុរិសា
សំខាន់ឃើញផ្លូវរួចចាកទុក្ខា
ឱ្យតែរអាបញ្ញាចាំងចែង ។
ក្រមុំមេម៉ាយតភ្ជាប់កុសលា

ដណ្តឹងបានការបតិសួគ៌ស្តែង

ក្រែបរសស្នេហានិងបុណ្យពុំលែង

បានសុខជាក់ស្តែងទោះមនុស្សទេវតា ។

ចេតោវិមុត្តិបញ្ញាវិមុត្តិ

ក្រមុំបរិសុទ្ធមេម៉ាយថ្លៃថ្លា

ព្រោះជ័យលាភីនៅក្នុងអាត្មា

រួចក្តីខ្លោចផ្សាកើតចាស់ឈឺស្លាប់ ។

ក្រមុំជូនបុណ្យមេម៉ាយសាទរ

ដួងចិត្តអំណរគ្មានក្តីស្រអ័ព្ធ

ទានវត្ថុដែលគ្រប់ទាំងដប់

ពិតជាប្រសព្វហៅសែនសំណាង ។

វីរិយាបុរសឆន្ទាអ្នកខ្លាំង

តស៊ូប្រឆាំងកិលេសកោងកាង

ខន្តីបុរសឈរលើកដៃឆ្កាង
អកុសលកុំសាងខ្លាចបាត់ក្រមុំ ។
សច្ចាបុរសសណ្ឋិតក្លាហាន
បុរសអធិដ្ឋាននៅតែរុំទុំ
ទានក្រមុំស្នេហ៍គ្មានឆ្នាស់បន្លំ
បុរសឧត្តមគឺអីចឹងឯង ។
សង្ខេបអត្ថន័យប្រុសស្រីគ្រប់ប្រាណ
ចងចាំឱ្យបានរៀនកុំរអែង
ការប្រៀបធៀបនេះសូមកុំចំបែង
រូបខ្ញុំមិនក្លែងយកធម៌លេងឡើយ ។
តែចង់ឱ្យយល់ពីធម៌ប្រណិត
តាំងពីព្រេងព្រឹទ្ធមានយូរណាស់ហើយ
ក្រមុំមេម៉ាយកម្លោះក៏ដោយ

សូមយកធម៌កើយជាខ្នើយសុខសាន្ត ។

សូមឱ្យបរិស័ទដែលជាធម្មមិត្ត

សូមអ្នកបាននិត្យព្រះធម៌កល្យាណ

រហូតសម្រេចនូវអមតៈឋាន

សូមឱ្យគ្រប់ប្រាណឃើញនិព្វានហោង ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ១៣-បណ្តាំអ្នករៀបរៀង



នាមខ្ញុំ**អក្ខរា**អ្នកតែងសៀវភៅ
បើខុសឬត្រូវសូមទានមេត្តា
ខ្ញុំសូមផ្តាំផ្ញើដល់បុត្រធីតា
ដែលខ្ញុំស្នេហាដូចជាបងប្អូន។
ពាក្យខ្ញុំផ្តាំផ្ញើគ្មានអ្វីធំដុំ
កម្លោះក្រមុំសូមអ្នកថែថួន
គោរពព្រះរស់ដែលនៅជិតខ្លួន
ឱ្យបានសមសួនជាកូនម៉ែឪ។
ប្រតិបត្តិព្រឹកល្ងាចកុំឱ្យមានទាស់
កុំមានចន្លោះធ្វើតាមផ្លូវត្រូវ
បម្រើពុកម្តាយគ្រប់ខែរដូវ
ពិតល្អពេកកូវសម្រាប់ប្រុសស្រី។
បើគាត់គ្មានសីលត្រូវនាំពុកម៉ែ

ថ្នមចិត្តហើយថែឱ្យបានប្រពៃ
នាំគាត់ទៅវត្តឱ្យបានរាល់ថ្ងៃ
នេះជាវិន័យសម្រាប់កូនៗ។
បើគាត់មិនចេះបរិច្ចាគទាន
មានទ្រព្យច្រើនលាននិងផ្ទះខ្លួន
ត្រូវប្រាប់រូបគាត់ថាឱ្យផ្ងួនៗ
ទើបឈ្មោះថាកូនមាតាបិតា។
កូនល្អតាំងខ្លួនក្នុងការដឹងគុណ
មិនធ្វើទារុណបង្កើតទុក្ខា
នាមយើងជាកូនកតញ្ញូតា
គួរតែរក្សាដោយហត្ថាផ្ចាល់។
សូមកូនទាំងឡាយត្រូវមានស្មារតី
ឱ្យបានឆ្លាតវៃកុំឲ្យអំពល់
ដឹងខ្លួនដឹងគុណលោកពុកនិមល
ម្យ៉ាងកុំរវល់រឿងបាបអីណា។

បំណាច់បម្រើចំពោះពុកម្តាយ
គួរកូនទាំងឡាយសាងក្តីសុខា
រួចអ្នកលើកជូនមាតាបិតា
នេះទើបឈ្មោះថាបម្រើពិតៗ។
ម្យ៉ាងអ្នកនិងខ្ញុំដែលមានជីវ៉ា
ដល់ពេលនេះណាអ្នកគួរតែគិត
គឺព្រោះពុកម៉ែដែគូពិសិដ្ឋ
ទើបមានជីវិតដល់សព្វថ្ងៃ។
ដូច្នេះសូមកូនគួរលើកហត្ថា
សំពះពុកវ៉ានិងអ្នកម៉ែថ្លៃ
ទាំងព្រឹកទាំងល្ងាចធ្វើប្រក្រតី
ធ្វើយប់ធ្វើថ្ងៃឱ្យបានប្រចាំ។
បើអ្នកមិនធ្វើបែបនឹងនោះទេ
អ្នកពិតឥតល្អែពីក្តីប្រេះស្រាំ
អ្នកពិតជួបទុក្ខរាប់ច្រើនជាតិឆ្នាំ

ដូច្នេះគួរចាំបើខុសគួរកែ។
សូមអ្នកគួរគិតឱ្យបានជាក់ច្បាស់
កុំបីក្រឡាស់គិតថ្ងៃដល់ខែ
គិតរឿងតបគុណចំពោះពុកម៉ែ
ទើបទេវតាស្នេហ៍គ្រប់ពេលវេលា។
បើពុំដូច្នោះពិតស្តាយក្រោយ
ម្យ៉ាងគ្មានកោះត្រើយគ្រប់អង្គា
អ្នកនិងបានទុក្ខសោកាគ្រាំគ្រា
ឈឺចាប់វេទនាគ្មានទំនេរ។
ធ្វើទៅបងប្អូនគ្រប់ៗអាត្មា
កុំឱ្យក្តៅផ្សាប្រេះបែកបែរ
បើអ្នកមិនធ្វើគឺឈឺឥតល្ហែ
អបាយមុខដែរនៅរងចាំរ៉ា។
សេចក្តីឈឺចាប់គ្មានជនណាឱ្យ
ដែលអ្នកបានកើយនឹងសិរសា

អ្នកកើយកាលណាបានក្តីឈឺផ្សា
ចុកចាប់ឱរាស្ទើររស់ស្ទើរស្លាប់។
រូបខ្ញុំសូមក្រើនដល់កូនប្រុសស្រី
គួរអ្នកគប្បីព្យាយាមប្រញាប់
ដឹងគុណតបគុណឱ្យបានឆាប់ៗ
នេះពិតមិនយ៉ាប់ទេពិសី។
យើងមានជីវិតរស់បានសប្បាយ
ទាំងរូបអង្គកាយក៏មិនរីងរៃ
កម្លាំងគ្រប់គ្រាន់ធ្វើជូនលោកថ្លៃ
នេះហើយប្រពៃណីរបស់បណ្ឌិត។
ខ្ញុំសូមត្រែកអរដល់កូនណា
គោរពមាតាបិតាដោយស្និទ្ធ
សូមឱ្យកូននោះមានតេជៈពិត
គ្រប់ជាតិសូមស្ថិតនឹងក្តីសុខា។
ឯកូនណាម្នាក់ធ្លាប់មើលងាយ

អ្នកគួរនិយាយសូមទោសា
ខមាទោសលោកទាំងពីរកាយា
ទើបស្រាលអាត្មាផុតហ្នឹងហ្នឹង។
ជាទីបញ្ចប់នាមខ្ញុំ**អក្ខរា**
សូមចែកផលាគឺបុណ្យនេះផង
សូមបានដល់ញាតិកុំបីកន្លង
បានសុខផុតឆ្គងលុះអវសាន្ត។
ជាពិសេសសូមជាបច្ច័យ
សូមញាតិប្រុសស្រីគ្រប់អង្គប្រាណ
ចូលដល់និព្វានកុំបីអាក់ខាន
ត្រែកអរគ្រប់ប្រាណសូមអនុមោទនា ។

**ដោយសុិន អក្ខរា ព.ស.២៥៥៦**

# ចប់



*រៀបរៀងដោយសាមណេរ* **២២៥** **ខន្តិសារោ សុិន អក្ខរា ព.ស.២៥៥៦**


សាមណេរ សុិន អក្ខរា
លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស